ក្រសួងកិច្ចការនារី





# សិទ្ធិ

## ក្រុមស្ត្រី និងក្មេងស្រីដែលងាយរងគ្រោះ

## ការប៉ាន់ប្រមាណអំពីយេនឌ័រនៅកម្ពុជា

២០១៤

រូបភាពគំរបមុខ

**ជឿន គីមហេង (២៤ឆ្នាំ)** ជាអ្នកបកប្រែព័ត៌មានអន្តរជាតិមកជាភាសាខ្មែរនៅស្ថានីយទូរទស្សន៍ជាតិកម្ពុជា ។ នាងវារឡើងលើកាំជណ្ដើរជារៀងរាល់ថ្ងៃ ដោយសារគ្មានផ្លូវជម្រាល ប៉ុន្តែនាងមិនដែលខ្វល់នោះទេ ។ នាងធ្វើការនេះ ដោយសារនាងគិតថា នាងអាចធ្វើវាបាន ។

# ជំពូកទី ៩

# សិទ្ធិ

## ក្រុមស្ត្រី និងក្មេងស្រី ដែលងាយរងគ្រោះ

### បរិបទគោលនយោបាយ និងច្បាប់សម្រាប់ក្រុមស្ត្រីដែលងាយរងគ្រោះ

សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ (CEDAW) បានផ្តល់នូវមូលដ្ឋានគ្រឹះសម្រាប់ការការពារសិទ្ធិស្ត្រី រាប់ទាំងស្ត្រីដែលមកពីក្រុមងាយរងគ្រោះ ឬស្ត្រីដែលមានតម្រូវការជាក់លាក់។ ប្រទេសកម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទក្នុងឆ្នាំ១៩៩២ និងពិធីសារតាមជម្រើសនៃអនុសញ្ញានេះក្នុងឆ្នាំ២០១០។

គណៈកម្មាធិការនៃអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ បានកំណត់ក្រុមស្ត្រីដែលងាយរងគ្រោះជាក់លាក់ ដែលគួរមានការសិក្សាស្រាវជ្រាវបន្ថែមទៀត និងគួរទទួលបានការយកចិត្តទុកដាក់ឱ្យកាន់តែច្រើនឡើងពីរដ្ឋាភិបាល រួមមាន៖ ១)ស្ត្រីពិការ ២)ស្ត្រីដែលមកពីក្រុមជនជាតិដើមភាគតិច ៣)ស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ និងក្រុមមនុស្សកែភេទ ៤)ស្ត្រីដែលត្រូវបានឃាត់ខ្លួន និងស្ត្រីជាប់ពន្ធនាគារ ៥)ស្ត្រីដែលមកពីតំបន់ជនបទ និងតំបន់ដាច់ស្រយាល ៦)ស្ត្រីដែលពាក់ព័ន្ធក្នុងសេវាផ្លូវភេទ ៧)ស្ត្រីដែលទទួលរងគ្រោះដោយសារអំពើហិង្សាផ្លូវភេទក្នុងអំឡុងរបបខ្មែរក្រហម ៨)ស្ត្រីដែលជាជនរងគ្រោះដោយសារការជួញដូរ ៩)កម្មការិនីរោងចក្រកាត់ដេរ អ្នកបម្រើតាមផ្ទះ និងជនចំណាកស្រុក និង១០)ស្ត្រីដែលមានផ្ទុកមេរោគអេដស៍។



▲ កម្ពុជាបានផ្តល់សច្ចាប័នលើសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនារីភេទ (CEDAW) នាឆ្នាំ១៩៩២ ។

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលបានអនុម័តក្នុងឆ្នាំ១៩៩៣ បានចែងអំពីសិទ្ធិស្មើគ្នាសម្រាប់ប្រជាជនកម្ពុជាទាំងអស់គ្នា៖ “ពលរដ្ឋខ្មែរមានភាពស្មើគ្នានៅចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និងករណីកិច្ចដូចគ្នាទាំងអស់ ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿសាសនា និន្នាការនយោបាយដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ” (មាត្រា ៣១)។

យុទ្ធសាស្ត្រជាតិគាំពារសង្គម សម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះ (ឆ្នាំ២០១១-២០១៥) មានគោលបំណងធានាថា ប្រជាជនកម្ពុជាទាំងអស់ទទួលបានផលប្រយោជន៍ពីការកែលម្អសំណាញ់សុវត្ថិភាពសង្គម និងសន្តិសុខសង្គម ដែលជាផ្នែកមួយដ៏សំខាន់នៃប្រព័ន្ធគាំពារសង្គមប្រកបដោយប្រសិទ្ធភាព។ គោលដៅចម្បង គឺការពារជនក្រីក្រ និងជនងាយរងគ្រោះកម្ពុជាពីភាពក្រីក្ររ៉ាំរ៉ៃ និងភាពអត់ឃ្លាន និងការផាត់ចេញពីសង្គម ក៏ដូចជាការផ្តល់ផលប្រយោជន៍ដល់ពួកគេពីការវិនិយោគធនធាន មនុស្សរបស់ខ្លួនជាដើម។

## បរិបទច្បាប់ និងគោលនយោបាយ សម្រាប់ស្ត្រីពិការ

អនុសញ្ញាស្តីពីសិទ្ធិជនពិការ (UNCRPD) ត្រូវបានចុះហត្ថលេខាដោយប្រទេសកម្ពុជាក្នុងឆ្នាំ ២០០៧ និងផ្តល់សច្ចាប័នក្នុងឆ្នាំ២០១២។ មាត្រា៦ នៃអនុសញ្ញាស្តីពីសិទ្ធិជនពិការចែងអំពីការរើសអើងជាច្រើនប្រភេទដែលស្ត្រីនិងក្មេងស្រីពិការបានជួបប្រទះ ចំណែកឯមាត្រា ៣ បានចែងអំពីសមភាពយេនឌ័រ ដែលជាគោលការណ៍ទូទៅ។

ច្បាប់ស្តីពីកិច្ចការពារ និងការលើកកម្ពស់សិទ្ធិជនពិការរបស់ប្រទេសកម្ពុជា ដែលត្រូវបានអនុម័តដោយរដ្ឋសភាក្នុងឆ្នាំ២០០៩ មានគោលដៅការពារសិទ្ធិ និងសេរីភាពរបស់ជនពិការ លុបបំបាត់ការរើសអើង និងជំរុញឱ្យមានការចូលរួមយ៉ាងពេញលេញរបស់ពួកគេនៅក្នុងសង្គម។ ទោះបីជានៅប្រទេសកម្ពុជាមានស្ត្រីពិការច្រើនជាងបុរសពិការក៏ដោយ ក៏នៅមិនទាន់មានឯកសារយោងជាក់លាក់ណាមួយ បានចែងអំពីស្ត្រីពិការនៅក្នុងច្បាប់ ឬចែងអំពីសិទ្ធិបន្តពូជ និងការលុបបំបាត់រាល់ទម្រង់នៃការរើសអើងជាក់លាក់ទៅលើស្ត្រីទាំងនោះនៅឡើយ។

ក្រុមប្រឹក្សាសកម្មភាពជនពិការ (DAC) និងគណៈកម្មាធិការ ដែលមានការរួមបញ្ចូលផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បានបង្កើតកម្មវិធីដើម្បីបញ្ចូលពិការភាពទៅក្នុងគោលនយោបាយអភិវឌ្ឍន៍ ដោយផ្តោតទៅលើវិស័យការងារ សុខាភិបាល និងអប់រំ និងយេនឌ័រ ដែលជាបញ្ហាអន្តរវិស័យ។

ផែនការសកម្មភាពជាតិ សម្រាប់ជនពិការ រួមមានអ្នករស់រានមានជីវិតពីគ្រាប់មីន និងគ្រឿងផ្ទុះ ដែលជាកាកសំណល់ពីសង្គ្រាម ត្រូវបានបង្កើតឡើង និងដឹកនាំដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងអាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន។ គោលបំណងមួយចំនួន គឺឆ្លើយតបទៅនឹងតម្រូវការយេនឌ័រ និងបង្ហាញយ៉ាងច្បាស់អំពីតម្រូវការរបស់ស្ត្រីពិការ។

គោលនយោបាយអប់រំ សម្រាប់កុមារពិការ (ឆ្នាំ២០០៨) និងផែនការមេនៃគោលនយោបាយនេះ មានគោលបំណងធានាថា កុមារពិការទាំងអស់មានសិទ្ធិទទួលបានការអប់រំដោយស្មើភាព។

វិធានការជាវិជ្ជមានផ្សេងៗទៀត ដែលបានចាត់ធ្វើឡើងដោយរាជរដ្ឋាភិបាលកម្ពុជាចំពោះជនពិការ រួមមានការស្នើសុំសេវាសុខាភិបាលដោយឥតគិតថ្លៃ សម្រាប់ពួកគេ

ព្រមទាំងចំនួនកូតាការងារ (ចំនួន ២ ភាគរយនៅតាមស្ថាប័នរដ្ឋាភិបាល/រដ្ឋ និងចំនួន ១ ភាគរយនៅតាមក្រុមហ៊ុននានា ដែលមានបុគ្គលិកចំនួនច្រើនជាង ១០០ នាក់។

## បរិបទគោលនយោបាយ សម្រាប់ស្ត្រីវ័យចំណាស់

សេចក្តីប្រកាសគោលនយោបាយ និងផែនការសកម្មភាពអន្តរជាតិក្រុងម៉ាឌ្រីដ ស្តីពីមនុស្សចាស់ (MIPAA) ត្រូវបានព្រមព្រៀងដោយប្រទេសចំនួន ១៥៩ ក្នុងឆ្នាំ២០០២ និងចុះហត្ថលេខាដោយប្រទេសកម្ពុជា គឺជាកិច្ចព្រមព្រៀងអន្តរជាតិទីមួយ ដែលទទួលស្គាល់អំពីតម្រូវការរបស់មនុស្សវ័យចំណាស់ទូទាំងពិភពលោក។ សេចក្តីប្រការនេះ គឺជាប្រភពនៃការតាក់តែងគោលនយោបាយសម្រាប់រដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងប្រតិបត្តិករផ្សេងទៀត ក្នុងការលើកកម្ពស់សុខុមាលភាពរបស់មនុស្សវ័យចំណាស់ និងភ្ជាប់បញ្ហាទាំងឡាយនៃមនុស្សចាស់ទៅក្របខណ្ឌផ្សេងទៀតសម្រាប់ការអភិវឌ្ឍន៍សង្គម និងសេដ្ឋកិច្ច និងសិទ្ធិមនុស្ស។ ទិន្នន័យបែងចែកតាមយេនឌ័រ និងវិធានការជាក់លាក់សម្រាប់ការផ្តល់ភាពអង់អាច និងការផ្តោតទៅលើតម្រូវការជាក់លាក់របស់ស្ត្រីវ័យចំណាស់ គឺមានបញ្ជាក់នៅក្នុងអនុសាសន៍ជាច្រើនរបស់ផែនការសកម្មភាពអន្តរជាតិក្រុងម៉ាឌ្រីដ ស្តីពីមនុស្សចាស់។

គោលនយោបាយជាតិសម្រាប់មនុស្សចាស់ (ឆ្នាំ២០០៣) ត្រូវបានតាក់តែងឡើងដើម្បីលើកឡើងអំពីកំណើននៃភាពងាយរងគ្រោះរបស់មនុស្សវ័យចំណាស់ ក្នុងគោលបំណងនៃការរួមបញ្ចូល និងការចូលរួមយ៉ាងពេញលេញពីមនុស្ស វ័យចំណាស់នៅក្នុងសង្គម។ គោលបំណងដ៏ចម្បងរបស់គោលនយោបាយជាតិសម្រាប់មនុស្សចាស់ គឺលើកកម្ពស់សុខុមាលភាពរបស់មនុស្សចាស់ និងធានាថាពួកគាត់ទទួលបានឱកាស និងអត្ថប្រយោជន៍ពីការអភិវឌ្ឍន៍ជាតិ។ គោលនយោបាយជាតិ សម្រាប់មនុស្សចាស់ លើកឡើង អំពីសុខុមាលភាពសង្គម ការថែទាំសុខភាព តម្រូវការផ្នែកសេដ្ឋកិច្ច និងការរួមបញ្ចូលមនុស្សចាស់ តាមរយៈការបង្កើតគោលដៅនៅក្នុងនយោបាយរបស់រដ្ឋាភិបាល ដើម្បីដោះស្រាយផ្នែកនីមួយៗទាំងអស់នេះ[1] ។

---

[1] អង្គការ HelpAge កម្ពុជា ២០១៤, *Gender and Emerging Issues with Focus on Ageing Population*

## បរិបទច្បាប់ សម្រាប់ស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ និងក្រុមមនុស្សកែភេទ

ការស្រឡាញ់មនុស្សមានភេទដូចគ្នា មិនមែនជារឿងមិនស្របច្បាប់នោះទេនៅក្នុងប្រទេសកម្ពុជា ហើយក៏គ្មានប្រពៃណីសាសនា ប្រឆាំងនឹងបុរសស្រឡាញ់បុរសផងដែរ[2] ។

ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារនៅក្នុងប្រទេសកម្ពុជា ដែលបានអនុម័តក្នុងឆ្នាំ១៩៨៩ បានចែងថា អាពាហ៍ពិពាហ៍គឺជាការសន្យាដ៏ឱឡារិកមួយ ដែលធ្វើឡើងដោយបុរសម្នាក់ និងស្ត្រីម្នាក់ (មាត្រា ៣) ចំណែកឯអាពាហ៍ពិពាហ៍ ដែលមានភេទដូចគ្នា ត្រូវបានហាមឃាត់ដាច់ខាត (មាត្រា ៦)។

ច្បាប់ស្តីពីការងារនៅក្នុងប្រទេសកម្ពុជា ដែលបានអនុម័តក្នុងឆ្នាំ១៩៩៧ មិនបានលើកឡើងអំពីនិន្នាការផ្លូវភេទ ឬអត្តសញ្ញាណផ្លូវភេទ ថាជាមូលដ្ឋានសម្រាប់រារាំងការរើសអើងនោះឡើយ។ មាត្រា ១២ ចែងអំពីសមភាពនៅក្នុងទីកន្លែងធ្វើការ ប៉ុន្តែមិនបានការពារស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរស ក្រុមមនុស្សស្រឡាញ់ទាំងពីរភេទ និងក្រុមមនុស្សកែភេទប្រកបដោយប្រសិទ្ធភាព ឬច្បាស់លាស់ឡើយ។

## បរិបទច្បាប់ និងគោលនយោបាយ សម្រាប់ស្ត្រី ដែលមកពីក្រុមជនជាតិដើមភាគតិច

ប្រទេសកម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់ការរើសអើងពូជសាសន៍ (ICERD) ក្នុងឆ្នាំ១៩៨៣។ ក្នុងឆ្នាំ២០០៧ រដ្ឋាភិបាលកម្ពុជាបានគាំទ្រការអនុម័តសេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិ ស្តីពីសិទ្ធិជនជាតិដើមភាគតិច (UNDRIP) ប៉ុន្តែមិនទាន់បានផ្តល់សច្ចាប័នលើអនុសញ្ញាលេខ ១៦៩ របស់អង្គការអន្តរជាតិខាងការងារនៅឡើយ។

ច្បាប់ភូមិបាលរបស់ប្រទេសកម្ពុជា (ឆ្នាំ២០០១) បានបង្កើតមូលដ្ឋានគ្រឹះ សម្រាប់ការចេញប័ណ្ណកម្មសិទ្ធិដីធ្លីសហគមន៍ នៅក្នុងសហគមន៍ជនជាតិដើមភាគតិច។ ច្បាប់នេះត្រូវបានបំពេញបន្ថែមដោយគោលនយោបាយស្តីពីការចុះបញ្ជី និងសិទ្ធិប្រើប្រាស់ដីរបស់សហគមន៍ជនជាតិដើមភាគតិច នៅក្នុងប្រទេសកម្ពុជា (ឆ្នាំ២០០៩) និងអនុក្រឹត្យស្តីពីនីតិវិធីនៃការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច។ ច្បាប់ស្តីពីព្រៃឈើ (ឆ្នាំ២០០២)

[2] មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ឆ្នាំ២០១០, *Coming Out in Cambodia*, Phnom Penh, Cambodia.



បានចែងយោងយ៉ាងច្បាស់លាស់អំពីកិច្ចគាំពារសិទ្ធិប្រើប្រាស់ជាប្រពៃណីរបស់សហគមន៍ជនជាតិដើមភាគតិច និងសិទ្ធិអនុវត្តកសិកម្មបែបពនេចរ[3]។

គោលនយោបាយជាតិស្តីពីការអភិវឌ្ឍន៍ជនជាតិដើមភាគតិច (ឆ្នាំ២០០៩) បានបង្កើតអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់ជនជាតិដើមភាគតិចលើផ្នែកវប្បធម៌ អប់រំ ការបណ្តុះបណ្តាលវិជ្ជាជីវៈ សុខាភិបាល បរិស្ថាន ដីកសិកម្ម ធនធានទឹក ហេដ្ឋារចនាសម្ព័ន្ធ យុត្តិធម៌ ទេសចរណ៍ និងឧស្សាហកម្ម រ៉ែ និងថាមពល។

▲ គោលនយោបាយជាតិសម្រាប់មនុស្សចាស់ជរាត្រូវបានបង្កើតដើម្បីបំពេញសេចក្តីត្រូវការរបស់មនុស្សចាស់ជរា

[3] The Indigenous World ឆ្នាំ២០១២, IWGIA, *The Indigenous World 2012*, Copenhagen, Denmark

## បញ្ឈប់ការរើសអើងទៅលើស្ត្រី និងក្មេងស្រីដែលមកពីក្រុមងាយរងគ្រោះ និងលើកកម្ពស់ការផ្តល់ភាពអង់អាច និងលទ្ធភាពទទួលបានធនធានប្រកបដោយផលិតភាពដល់ពួកគេ។

ក្រុមដែលងាយរងគ្រោះ គឺជាសមាជិកមួយរបស់សង្គមដែលទទួលអត្ថប្រយោជន៍តិចតួច ឬប្រឈមនឹងហានិភ័យខ្ពស់នៅក្នុងការទទួលរងគ្រោះដោយសារបញ្ហាមួយ ឬច្រើនដែលធ្វើឱ្យប៉ះពាល់ដល់សង្គម។ ស្ត្រី និងក្មេងស្រីដែលមកពីក្រុមងាយរងគ្រោះ ទំនងជាធ្លាប់ទទួលរងគ្រោះដោយសារការរំលោភសិទ្ធិមនុស្សជាមូលដ្ឋានរបស់ខ្លួន បើប្រៀបធៀបទៅនឹងបុរស រាប់ទាំងបុរសដែលមកពីក្រុមងាយរងគ្រោះដូចគ្នា និងស្ត្រីដទៃទៀតផងដែរ។

ជាញឹកញាប់ ហានិភ័យកាន់តែខ្ពស់ក្នុងការទទួលរងគ្រោះដោយអំពើហិង្សា និងអំពើហិង្សាទាក់ទងនឹងយេនឌ័រ ព្រមទាំងជួបប្រទះបញ្ហាជាច្រើនក្នុងការទទួលបាននូវសេវា និងធនធានសាធារណៈ ដូចជាសេវាសុខាភិបាល អប់រំ និងយុត្តិធម៌ជាដើម ដែលនាំឱ្យពួកគាត់កាន់តែក្រីក្រ និងងាយប្រឈមនឹងហានិភ័យខ្ពស់ចំពោះភាពក្រីក្រ និងការមានសុខភាពកាន់តែដុនដាប។

គោលនយោបាយ និងវិធានការផ្លូវច្បាប់ជាក់លាក់ និងជាវិជ្ជមាន គឺមានសារៈសំខាន់នៅក្នុងការកែលម្អស្ថានភាពរបស់ស្ត្រី និងក្មេងស្រីដែលមកពីក្រុមដែលងាយរងគ្រោះ។ លើសពីនេះទៀត តម្រូវឱ្យមានកម្មវិធីជាបន្ថែម ទៀត ក្នុងការលើកកម្ពស់វប្បធម៌ និងការផ្លាស់ប្តូរថ្មីៗ ដែលពិចារណាទៅលើស្ត្រី និងក្មេងស្រី ជាពិសេសស្ត្រី និងក្មេងស្រីដែលមកពីក្រុមងាយរងគ្រោះ ដែលជាការរួមចំណែកដ៏មានតម្លៃ និងប្រកបដោយសមភាព។

## ការកំណត់អត្តសញ្ញាណក្រុមស្ត្រីនិងក្មេងស្រីដែលងាយរងគ្រោះ៖

យុទ្ធសាស្ត្រជាតិគាំពារសង្គមរបស់រដ្ឋាភិបាល កម្ពុជាសម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះ ឆ្នាំ២០១១-២០១៥ កំណត់ក្រុមដែលងាយរងគ្រោះ មានដូចតទៅ៖ ១.ទារក និងកុមារ ២.ក្មេងស្រី និងស្ត្រីក្នុងវ័យបន្តពូជ ៣.គ្រួសារងាយទទួលរងគ្រោះដោយសារអសន្តិសុខស្បៀងនិងភាពអត់ការងារធ្វើ ៤.ជនជាតិដើមភាគតិចនិងជនជាតិភាគតិច ៥.ស្ត្រីវ័យចំណាស់ ៦.អ្នកដែលមានជំងឺរ៉ាំរ៉ៃ រួមទាំងអ្នកមានផ្ទុកមេរោគអេដស៍ ៧.ជនពិការ ៨.ក្មេងកំព្រា ៩.កុមារនិងយុវវ័យដែលប្រឈមនឹងគ្រោះថ្នាក់ ១០.ជនរងគ្រោះដោយសារអំពើហិង្សា ការរំលោភបំពាននិងការកេងប្រវ័ញ្ច ១១.គ្រួសារជនធ្វើចំណាកស្រុក

១២.អ្នកដែលគ្មានទីជម្រក ១៣.អតីតយុទ្ធជន ១៤.ស្ត្រីជាមេគ្រួសារ ១៥.ស្ត្រីមេម៉ាយ ១៦.ស្ត្រីមានផ្ទៃពោះនិង១៧.ពលករកុមារ។

វិធីសាស្ត្រឆ្លើយតបដ៏មានប្រសិទ្ធភាព និងដែលផ្តោតការយកចិត្តទុកដាក់លើយេនឌ័រ គឺការគិតគូរដល់ស្ត្រី និងក្មេងស្រីដែលមកពីក្រុមងាយរងគ្រោះ ឬស្ត្រីនិងក្មេងស្រីដែលមានតម្រូវការជាក់លាក់។ ក្រុមមនុស្សទាំងនេះ រួមមានស្ត្រី និងក្មេងស្រីពិការ ស្ត្រីវ័យចំណាស់ ស្ត្រីមេម៉ាយ និងស្ត្រីជាមេគ្រួសារ ស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ និងក្រុមមនុស្សកែភេទ ស្ត្រីនិងក្មេងស្រីដែលមកពីក្រុមជនជាតិដើមភាគតិចនិងក្រុមជនជាតិភាគតិច ស្ត្រីទទួលរងគ្រោះដោយសារអំពើហិង្សាទាក់ទងនឹងយេនឌ័រនិងកូនរបស់ពួកគាត់ ស្ត្រីដែលធ្លាប់ទទួលរងគ្រោះដោយសារអំពើហិង្សាផ្លូវភេទ និងឬការរៀបការដោយបង្ខំក្នុងអំឡុងរបបខ្មែរក្រហម ស្ត្រីនិងក្មេងស្រីដែលមានផ្ទុកមេរោគអេដស៍ ស្ត្រីនិងក្មេងស្រីដែលរស់នៅតំបន់ដាច់ស្រយាល ស្រីជាប់ពន្ធនាគារ និងស្ត្រីដែលពាក់ព័ន្ធក្នុងសេវាផ្លូវភេទ និងឬស្ត្រីដែលធ្វើការនៅទីកន្លែងកំសាន្តរបស់បុរស[4]។

មានករណីខ្លះ ស្ត្រី និងក្មេងស្រីម្នាក់អាចក្លាយជាជនរងគ្រោះលើច្រើនករណី ក្នុងពេលតែមួយ។ ឧទាហរណ៍ស្ត្រីម្នាក់ ជាជនពិការផង ជាជនវ័យចំណាស់ផង និងរស់នៅតំបន់ដាច់ស្រយាល។ ក្នុងករណីខ្លះទៀត ស្ត្រីទទួលរងគ្រោះដោយសារអំពើហិង្សាទាក់ទងនឹងយេនឌ័រផង និងមានផ្ទុកមេរោគអេដស៍ផង។

## ប្រជាសាស្ត្រនៃក្រុមស្ត្រី និងក្មេងស្រី ដែលងាយរងគ្រោះ៖

### ស្ត្រីពិការ៖

- ប្រជាជនកម្ពុជាចំនួន២,១ភាគរយ មានពិការភាពយ៉ាងហោចណាស់ក៏ផ្នែកណាមួយដែរ (ចំនួន៣០៨.២០៨ នាក់)[5]។ ទោះជាយ៉ាងណាក៏ដោយ ការព្យាករណ៍ជាសាកល និងអ្នកជំនាញនានាបានកំណត់ថានៅប្រទេសកម្ពុជា ស្ថិតិនៃពិការភាពប្រហែលជាមិនទាន់ត្រូវបានរាយការណ៍ឱ្យបានអស់នៅឡើយ។

[4] ព័ត៌មានជាបន្ថែមអំពីស្ត្រី និងក្មេងស្រី ដែលទទួលរងគ្រោះដោយសារអំពើហិង្សាទាក់ទងនឹងយេនឌ័រ ហើយស្ត្រី និងក្មេងស្រីដែលមានផ្ទុកមេរោគអេដស៍ អាចរកបាននៅក្នុងឯកសារសង្ខេបគោលនយោបាយស្តីពីអំពើហិង្សាលើស្ត្រី និងជំងឺអេដស៍នៃឯកសារប៉ាន់ប្រមាណយេនឌ័រនៅកម្ពុជា ឆ្នាំ ២០១៤។

[5] អង្កេតចន្លោះជំរឿនកម្ពុជា វិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ ឆ្នាំ២០១៣

- ៥២,២ភាគរយនៃជនពិការ គឺជាបុរស ហើយ ៤៧,៨ ភាគរយ គឺជាស្ត្រី[6] ។
- ស្ត្រីពិការមានចំនួនច្រើន បើប្រៀបធៀបទៅនឹងបុរសពិការ ដូចជាការលំបាកផ្នែកចក្ខុវិញ្ញាណ (៣៨,៦ភាគរយជាស្ត្រី និង៣១,៤ភាគរយជាបុរស) ការលំបាកក្នុងការនិយាយស្តី (៦,៥ភាគរយជាស្ត្រី និង៤,៤ភាគរយជាបុរស) និងពិការភាពផ្នែកសតិបញ្ញា (១៤,៧ភាគរយជាស្ត្រី និង៩,៨ ភាគរយជាបុរស)។ ផ្ទុយទៅវិញ បុរសពិការមានចំនួនច្រើន បើប្រៀបធៀបនឹងស្ត្រី ពិការ ដូចជាការលំបាកក្នុងការធ្វើចលនា (៤១,៤ ភាគរយជាបុរស និង២៤,៧ភាគរយជាស្ត្រី)[7]។ មូលហេតុនៃភាពអន់ខ្សោយផ្នែករាងកាយមានច្រើនពីកំណើត (២០,៤ភាគរយជាស្ត្រីដែលមានភាពអន់ខ្សោយផ្នែករាងកាយ និង១៩,៥ភាគរយជាបុរស) ដោយសារជំងឺ (៤៦ភាគរយជាស្ត្រី និង២៦,៦ភាគរយជាបុរស) ដោយសារមីន (៤ភាគរយជាស្ត្រី និង១៦,១ភាគរយជាបុរស) ដោយសារអាវុធ (១,៦ភាគរយជាស្ត្រី និង៧,២ភាគរយជាបុរស) ដោយគ្រោះថ្នាក់ចរាចរណ៍ (៩,៩ភាគរយជាស្ត្រី និង១០,១ភាគរយជាបុរស) និងគ្រោះថ្នាក់ផ្សេងៗទៀត (១៨,១ភាគរយជាស្ត្រី និង២០,២ ភាគរយជាបុរស)[8] ។
- បើទោះបីជាមានបុរស ដែលមានភាពអន់ខ្សោយផ្នែករាងកាយ ចំនួនច្រើនជាងស្ត្រីនៅក្នុងប្រទេសកម្ពុជាក៏ដោយ ក៏ស្ត្រីដែលមានភាពអន់ខ្សោយផ្នែករាងកាយដោយសារតែមានជំងឺ មានចំនួនស្ទើរតែពីរដងនៃចំនួនបុរស[9] ។
- អាយុជាមធ្យមនៃជនពិការ គឺ៤៥,៧៦ឆ្នាំ ចំណែកឯអាយុជាមធ្យមនៃជនពិការទាំងអស់ គឺ២៤,៥២ឆ្នាំ។ អាយុជាមធ្យមនៃបុរស និងស្ត្រី ក្នុងចំណោមជនពិការ គឺ៤៤,៩៣ឆ្នាំ (ចំពោះបុរស) និង៤៧,០១ឆ្នាំ (ចំពោះស្ត្រី)[10] ។

## ស្ត្រីវ័យចំណាស់៖

- ប្រជាជនកម្ពុជា ចំនួន៦,៣៤ភាគរយ មានអាយុច្រើនជាង ៦០ឆ្នាំ ដោយក្នុងនោះ

---

6 CIPS ឆ្នាំ២០១៣
7 អង្កេតចន្លោះជំរឿនកម្ពុជា វិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ ឆ្នាំ២០១៣
8 អង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ក្រសួងផែនការ ឆ្នាំ២០១៣
9 អង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ក្រសួងផែនការ ឆ្នាំ២០១៣
10 អង្កេតចន្លោះជំរឿនកម្ពុជា វិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ ឆ្នាំ២០១៣



▲ មនុស្សចាស់ជរាមានការលំបាកក្នុងការសន្សំថវិកាក្នុងមុខរបររបស់ពួកគាត់

៥៨ភាគរយគឺជាស្ត្រី និង៤២ ភាគរយគឺជាបុរស[11] ។

- ភាគរយនៃប្រជាជនកម្ពុជា ដែលមានអាយុច្រើនជាង ៦០ឆ្នាំ ទំនងជាមានដល់១៩ភាគរយ ក្នុងឆ្នាំ២០៥០ ដោយសារតែមានការធ្លាក់ចុះនៃអត្រាផ្តល់កំណើត និងការកើនឡើងនៃអាយុសង្ឃឹមរស់[12] ។
- ស្ត្រីចំនួន៣០,៥ភាគរយ ដែលយ៉ាងហោចណាស់មានពិការភាពផ្នែកណាមួយ ឬមានការលំបាកនៅផ្នែកណាមួយមានអាយុលើសពី៦០ឆ្នាំ បើប្រៀបធៀបទៅនឹងបុរស គឺមានចំនួន២៥,៥ភាគរយ[13] ។

## ស្ត្រីមេម៉ាយ និងស្ត្រីជាមេគ្រួសារ៖

- ស្ត្រីចំនួន១៣ភាគរយ ជាស្ត្រីមេម៉ាយ (ស្ត្រីចំនួន ៩៥៦.៩៣០នាក់)

[11] ជំរឿនប្រជាជនកម្ពុជាឆ្នាំ២០០៨ ក្រសួងផែនការ

[12] *Ageing and Migration in Cambodia: A CRUMP Series Report* ក្រសួងផែនការ ឆ្នាំ២០១៣

[13] អង្កេតសេដ្ឋកិច្ច និងសង្គមកិច្ច កម្ពុជា ២០១២ ក្រសួងផែនការ

បើប្រៀបធៀបទៅនឹងបុរសចំនួន ២,៣ភាគរយ (បុរសចំនួន១៦១.៣៤៥នាក់)។ បញ្ហានេះគឺដោយសារតែមានមូលហេតុដូចតទៅៈ ក)ជាទូទៅប្រពន្ធមានអាយុក្មេងជាងប្តី ខ)ស្ត្រីមានអាយុសង្ឃឹមរស់ខ្ពស់ជាងបុរស និងគ)បុរសទំនងជារៀបការជាថ្មីទៀតក្នុងចំនួនសមាមាត្រមួយ ដែលខ្ពស់ច្រើនជាងចំនួនសមាមាត្រនៃស្ត្រី [14]។

- គ្រួសារចំនួន២២ភាគរយមានស្ត្រីជាមេគ្រួសារ (គ្រួសារចំនួន៦៧៨.០៤០)។ ភាគរយនេះមានកម្រិតកាន់តែខ្ពស់នៅរាជធានីភ្នំពេញ (២៤,៩ភាគរយ ទល់នឹង ២០,៧ភាគរយ នៅតំបន់ជនបទ) [15] ។

## ស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ភេទទាំងពីរ និងក្រុមមនុស្សកែភេទៈ

- នៅប្រទេសកម្ពុជា មិនទាន់មានការប៉ាន់ប្រមាណអំពីតួលេខនៃស្ត្រីស្រឡាញ់ស្ត្រី និងបុរស ស្រឡាញ់បុរសនៅឡើយ។ ផ្អែកតាមការប៉ាន់ស្មានអំពីតួលេខខុសៗគ្នាពីមុនៗមករបស់ ប្រទេសមួយចំនួន (រួមមានប្រទេសអូស្ត្រាលី បារាំង សហរដ្ឋអាមេរិក កាណាដា ណូវែលសេឡង់ អេស្ប៉ាញ និងចក្រភពអង់គ្លេស[16]) បានបង្ហាញឱ្យឃើញថាប្រជាជនកម្ពុជា ចំនួនចន្លោះពី ១ទៅ១០ភាគរយ អាចជាមនុស្សស្រឡាញ់ភេទដូចគ្នា (ចំនួនចន្លោះ ពី១៤៧.០០០នាក់ទៅ ១,៤៧លាននាក់)។
- ខណៈដែលមិនមានតួលេខប៉ាន់ស្មាន អំពីចំនួនក្រុមមនុស្សកែភេទនៅក្នុងប្រទេសកម្ពុជានៅ ឡើយនោះ អត្រាប៉ាន់ប្រមាណពីការសិក្សាផ្នែកវេជ្ជសាស្ត្រនៅក្នុងសហរដ្ឋអាមេរិក និងបណ្តាប្រទេសនៅប៉ែកអឺរ៉ុបខាងជើង (ដូចជាប្រទេសស៊ុយអ៊ែត ចក្រភពអង់គ្លេស និងប្រទេសហូឡង់) បានបញ្ជាក់ថានៅប្រទេសកម្ពុជាអាចមានបុរស១នាក់ ក្នុងចំណោមបុរស ចំនួនពី២.៩០០នាក់ទៅ ១០០.០០០នាក់ បានកែភេទពីបុរសទៅជាស្ត្រី (ចំនួនចន្លោះពី ១៤៧នាក់ទៅ៥.០៦១នាក់) ហើយអាចមានស្ត្រី១នាក់ក្នុងចំណោមស្ត្រី

[14] Ibid

[15] Ibid

[16] Smith AM, Rissel CE, Richters J, Grulich AE, de Visser RO, Sex in Australia: the rationale and methods of the Australian Study of Health and Relationship, 2003; AIDS and sexual behavior in France. Mostly Indian girls are affected from France girls, ACSF investigators. Nature 360, 1992; Sax on Sex: The emerging science of sex differences, Psychology Today, 3 April 2010; King et al., Canada, Youth and AIDS Study. Kingston, On: Queen´s University, 1988.

ចំនួនពី៨.៣០០នាក់ ទៅ៤០០.០០០នាក់ បានកែភេទពីស្ត្រីទៅជាបុរស (ចំនួនចន្លោះពី៣៧នាក់ ទៅ១.៧៦៨នាក់)[17]។

## ស្ត្រីដែលមកពីក្រុមជនជាតិដើមភាគតិច និងជនជាតិភាគតិច៖

- ស្ត្រីកម្ពុជា៩៦,៣៦ភាគរយ និយាយភាសាខ្មែរ ដែលជាភាសាកំណើត រីឯ ០,៥២ភាគរយនិយាយភាសាវៀតណាម ០,១៤ភាគរយនិយាយភាសាឡាវ ០,០៤ភាគរយនិយាយភាសាចិន ០,០១ភាគរយនិយាយភាសាថៃ និង២,៨៦ ភាគរយនិយាយភាសាជនជាតិដើមភាគតិច[18]។

- នៅក្នុងប្រទេសកម្ពុជា មានជនជាតិដើមភាគតិច២៤ក្រុម ដែលគេហៅថាខ្មែរលើ (កុលសម្ព័ន្ធភ្នំ) ដោយមានសហគមន៍ជនជាតិដើមភាគតិចកំពុងតែរស់នៅរាយប៉ាយក្នុងខេត្តចំនួន១៥។

- ប្រជាជនកម្ពុជា ៣៨៣.២៧៣នាក់ និយាយភាសាជនជាតិដើមភាគតិច ដែលជាភាសាកំណើត ក្នុងនោះមានស្ត្រីចំនួន១៩៦.៦៤២នាក់ (៥១,៣ភាគរយ)។ ប្រជាជន ៥៣,៥៧ភាគរយនិយាយភាសាចាមដែលជាភាសាកំណើត ចំនួន៩,៦១ភាគរយនិយាយភាសាព្នង ចំនួន៧,៩៦ភាគរយនិយាយភាសាទំពូន ចំនួន៧,៥៤ភាគរយនិយាយភាសាគួយ ចំនួន៦,៨២ភាគរយនិយាយភាសាចារាយ ៥,១៨ភាគរយនិយាយភាសាគ្រឹង និង៩,៣២ភាគរយនិយាយភាសាផ្សេងទៀត[19] ។

- ស្ត្រីកម្ពុជាចំនួន៩៦,៩៦ភាគរយកាន់សាសនាព្រះពុទ្ធ ១,៩២ភាគរយកាន់សាសនាអ៊ីស្លាម ០,៣៩ ភាគរយកាន់សាសនាគ្រិស្ត និង០,៧៩ភាគរយកាន់សាសនាផ្សេងៗទៀត[20] ។

## ស្ត្រីដែលធ្លាប់ទទួលរងគ្រោះដោយសារអំពើហិង្សាផ្លូវភេទ និងឬការរៀបការដោយបង្ខំក្នុងអំឡុងរបបខ្មែរក្រហម៖

- ចំនួនដ៏ខ្ពស់មួយដែលមិនទាន់បានកំណត់នៅឡើយនៃស្ត្រីដែលធ្លាប់ទទួលរងគ្រោះ

---

[17] អត្ថបទប្រាវជ្រាវ ឧបទ្ទវហេតុ និងភេទនៃការកែភេទ Acta Psychiatrica Scandinavica ឆ្នាំ ១៩៩៦។
[18] ជំរឿនប្រជាជនកម្ពុជាឆ្នាំ២០០៨
[19] ជំរឿនប្រជាជនកម្ពុជាឆ្នាំ២០០៨
[20] ជំរឿនប្រជាជនកម្ពុជា ២០០៨

ដោយសារអំពើហិង្សាផ្លូវភេទក្នុងអំឡុងរបបខ្មែរក្រហម ដែលស្ទើរតែគ្រប់ករណី គឺដោយសារភ្នាក់ងារខ្មែរក្រហម។ អំពើហិង្សាផ្លូវភេទទាំងនោះ រួមមានអំពើរំលោភសេពសន្ថវៈ អំពើរំលោភសេពសន្ថវៈជាក្រុម (មានន័យថារំលោភបូកដែលប្រព្រឹត្តដោយជនល្មើសច្រើននាក់) អំពើរំលោភសេពសន្ថវៈ ទ្រង់ទ្រាយធំ (មានន័យថារំលោភជនរងគ្រោះច្រើននាក់) ទាសភាពផ្លូវភេទ និងអំពើរួមភេទដើម្បី បន្តមានជីវិត (មានន័យថាការរួមភេទដើម្បីដោះដូរអាហារ ថ្នាំពេទ្យ ឬទទួលបានការងារស្រាល) ឬអំពើរំលោភសេពសន្ថវៈមុនពេលសម្លាប់។ នៅក្នុងពេលប្រព្រឹត្តអំពើរំលោភសេពសន្ថវៈ ជនល្មើសតែងតែបានវាយដំ និងធ្វើទារុណកម្មជនរងគ្រោះ ដែលជួនកាលគឺទុកពួកគេចោលរហូតដល់ស្លាប់[21] ។

- ស្ត្រី និងបុរសចំនួនរាប់ពាន់ត្រូវបានខ្មែរក្រហមបង្ខិតបង្ខំឱ្យរៀបការ ដើម្បីមានកូនជាមួយសហព័ទ្ធ ថ្មីរបស់ខ្លួន[22] ។

## ស្ត្រីជាប់ពន្ធនាគារ៖

នៅក្នុងឆ្នាំ២០១២ មានប្រជាជនជាប់ពន្ធនាគារចំនួន១៥.៣៩៧នាក់ ហើយចំនួន ៨,១៩ភាគរយនៃពួកគេ (ចំនួន ១.២៦១នាក់) ជាស្ត្រី[23]។

## ហានិភ័យដ៏ខ្ពស់នៃការរើសអើងស្លាកស្នាមរងគ្រោះ អំពើហិង្សា និងអំពើហិង្សាទាក់ទងនឹងយេនឌ័រ៖

ស្ត្រី និងក្មេងស្រីដែលមកពីក្រុមងាយរងគ្រោះ ជារឿយៗ ប្រឈមនឹងទម្រង់ជាច្រើននៃការរើសអើងដែលរួមមានការស្តីបន្ទោស ការរំលោភបំពានជាពាក្យសម្តីនិងការរំលោភបំពានផ្លូវកាយពី សំណាក់សមាជិកគ្រួសារ អ្នកជិតខាង សមាជិកដែលរស់នៅក្នុងសហគមន៍ជាមួយគ្នា សហការីរួមការងារ ឬមន្ត្រីសាធារណៈ និងប្រព័ន្ធផ្សព្វផ្សាយ។ ការរើសអើង និងអំពើហិង្សា ដែលស្ត្រីមកពីក្រុមងាយរងគ្រោះបានជួបប្រទះធ្វើឱ្យស្ត្រីបាត់បង់ភាពអង់អាច និងបាត់មុខបាត់មាត់ក្នុងជីវិតសាធារណៈនៅក្នុងសហគមន៍របស់ពួកគេ រួមទាំងតួនាទីនៅក្នុងផ្នែកនយោបាយ និងតួនាទីក្នុងការធ្វើសេចក្តីសម្រេច។ ពុំទាន់មានចំនួនកូតា

[21] អង្គការក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា ឆ្នាំ២០១៤ (Theresa de Langis, *"Moral Offenses" and Sexual Violations against Women Under the Khmer Rouge Regime*, Code 6)

[22] ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា ឆ្នាំ២០១៤

[23] ទិន្នន័យពីក្រសួងមហាផ្ទៃ គិតត្រឹមថ្ងៃទី ១៥ ខែវិច្ឆិកា ឆ្នាំ២០១២។



សម្រាប់ឱ្យមានតំណាងស្មើភាគ មកពីក្រុមងាយរងគ្រោះនៅក្នុងការងាររាជការ និងការងារនយោបាយនៅឡើយ។

▲ មានជនជាតិដើមភាគតិចចំនួន២៤ក្រុមរស់នៅក្នុងប្រទេសកម្ពុជា

## ស្ត្រីពិការ៖

- ស្ត្រីពិការងាយនឹងទទួលរងគ្រោះដោយសារអំពើហិង្សាពីសំណាក់សមាជិកគ្រួសារ ដែលមិនមែនជាដៃគូរបស់ខ្លួន បើប្រៀបធៀបទៅនឹងស្ត្រីមិនមានពិការភាព។ បើយោងតាមការសិក្សាស្រាវជ្រាវអំពីទណ្ឌកម្មត្រីគុណ បានឱ្យដឹងថាស្ត្រីពិការ ២៥ភាគរយ ដែលបានចូលរួមនៅក្នុងការធ្វើអង្កេតនេះ ធ្លាប់ទទួលរងគ្រោះដោយសារអំពើហិង្សាផ្លូវកាយពីសំណាក់សមាជិកគ្រួសារ បើប្រៀបធៀបទៅនឹងស្ត្រីមិនមានពិការភាព ដែលមានចំនួន ១១,៤ភាគរយ ខណៈដែលស្ត្រី៥២,៥ភាគរយ បានរាយការណ៍អំពីការរំលោភបំពានផ្លូវចិត្ត និង៥,៧ភាគរយ

បានរាយការណ៍អំពីអំពើហិង្សាផ្លូវភេទពីសំណាក់សមាជិកគ្រួសារ[24]។

- អំពើហិង្សាទាក់ទងនឹងយេនឌ័រ គឺជាកត្តារួមចំណែកមួយចំពោះស្ត្រីពិការ៖ មួយភាគបួននៃស្ត្រី ដែលទទួលរងគ្រោះដោយសារអំពើហិង្សាក្នុងគ្រួសារ មានជំងឺផ្លូវកាយ ឬការស្រកទម្ងន់ដោយសារតែអំពើហិង្សានេះ។ស្ត្រី៦៦ភាគរយមានការថប់អារម្មណ៍ ភ័យខ្លាច ឬការធ្លាក់ទឹកចិត្ត។ ស្ត្រី៦៨ ភាគរយគេងមិនលក់ និង១២ភាគរយទៀតបានសារភាពអំពីការចង់ធ្វើអត្តឃាត[25]។

## ស្ត្រីស្រឡាញ់ស្ត្រី និងក្រុមមនុស្សកែភេទ៖

- បើយោងតាមលទ្ធផលនៃការធ្វើសម្ភាសន៍បែបគុណភាពជាមួយក្រុមស្ត្រីស្រឡាញ់ស្ត្រី ក្រុមបុរសស្រឡាញ់បុរស ក្រុមមនុស្សស្រឡាញ់ទាំងពីរភេទ និងក្រុមមនុស្សកែភេទចំនួន៦០នាក់នៅក្នុងប្រទេសកម្ពុជា បានបង្ហាញឱ្យឃើញថាទំនាក់ទំនងគ្នារបស់ស្ត្រីស្រឡាញ់ស្ត្រីត្រូវប្រឈមទៅនឹងការរើសអើង និងអាចបណ្តាលឱ្យមានស្ថានភាពមួយដែលសមាជិកគ្រួសារប្រើមធ្យោបាយច្រើនយ៉ាងដើម្បីប៉ុនប៉ងបំបែកបំបាក់ទំនាក់ទំនងស្នេហារវាងភេទដូចគ្នានេះ[26]។

- របាយការណ៍មួយចំនួនទៀតបានបង្ហាញថាក្រុមមនុស្សកែភេទដែលពាក់ព័ន្ធក្នុងសេវាផ្លូវភេទ បានប្រឈមទៅនឹងការរើសអើង ហើយពេលខ្លះបានទទួលរងគ្រោះដោយសារអំពើហិង្សាពីសំណាក់នគរបាលទៀតផង[27]។

- ស្ត្រីស្រឡាញ់ស្ត្រី និងក្រុមមនុស្សកែភេទ បើគិតជាសមាមាត្រ ធ្លាប់ទទួលរងគ្រោះដោយសារអំពើហិង្សាច្រើនជាងស្ត្រីដែលធ្លាប់រៀបការ ផ្អែកតាមការប្រៀបធៀបរវាងទិន្នន័យនៃការធ្វើអង្កេតប្រជាសាស្ត្រនិងសុខភាព ឆ្នាំ២០០៥ និងការសិក្សាស្រាវជ្រាវមួយទៅលើក្រុមស្ត្រីស្រឡាញ់ស្ត្រី ក្រុមមនុស្សស្រឡាញ់ទាំងពីរភេទ និងក្រុមមនុស្សកែភេទ សរុបចំនួន១៤៩នាក់[28]។

---

24 ការសិក្សាស្រាវជ្រាវអំពីទណ្ឌកម្មត្រីគុណៈ អំពើហិង្សាទាក់ទងនឹងយេនឌ័រ និងការរំលោភសិទ្ធិមនុស្ស ដែលស្ត្រីពិការធ្លាប់ទទួលរងគ្រោះនៅក្នុងប្រទេសកម្ពុជា AusAID ឆ្នាំ២០១៣។

25 អំពើហិង្សាលើស្ត្រីៈ ការធ្វើអង្កេតពិនិត្យតាមដាន ឆ្នាំ២០០៩ ក្រសួងកិច្ចការនារី ឆ្នាំ២០១០។

26 ការចេញមកក្រៅ នៅក្នុងប្រទេសកម្ពុជា មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ឆ្នាំ២០១០។

27 ការចេញមកក្រៅ នៅក្នុងប្រទេសកម្ពុជា មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ឆ្នាំ២០១០។

28 Vicente S. Salas, ការរុករកមួយអំពីការផាត់ចេញពីសង្គមនៃក្រុមស្ត្រីស្រឡាញ់ស្ត្រី ក្រុមបុរសស្រឡាញ់បុរស និងក្រុមមនុស្សកែភេទ នៅក្នុងគ្រួសារ និងសហគមន៍ អង្គភាពសម្របសម្រួលកិច្ចគាំពារសង្គម-មូលនិធិនៃការសិក្សាស្រាវជ្រាវអំពីកិច្ចគាំពារសង្គមនៅកម្ពុជា ឆ្នាំ ២០១៣។

## ស្ត្រី ដែលពាក់ព័ន្ធក្នុងសេវាផ្លូវភេទ៖

- ការសិក្សាស្រាវជ្រាវមួយចំនួន បានកំណត់ថាអំពើរំលោភសេពសន្ថវៈជាក្រុម (ការរំលោភបូក) ដែលជារឿយៗប្រព្រឹត្តទៅលើក្រុមស្ត្រីដែលពាក់ព័ន្ធក្នុងសេវាផ្លូវភេទ ត្រូវបានទទួលស្គាល់ជាទូទៅថាជាសកម្មភាពកំសាន្តមួយខាងផ្លូវភេទក្នុងចំណោមយុវជន ជាពិសេសនៅក្នុងតំបន់ទីប្រជុំជន។ ការសិក្សាស្រាវជ្រាវរបស់អង្គការដៃគូសម្រាប់ការទប់ស្កាត់ ឆ្នាំ២០១២ បានរកឃើញថាបុរស៥ភាគរយបានរាយការណ៍ អំពីការចូលរួមនៅក្នុងការរំលោភបូកទៅលើស្ត្រី។ អត្រានេះកាន់តែខ្ពស់ បើប្រៀបធៀបទៅនឹងប្រទេសផ្សេងៗទៀតនៅក្នុងតំបន់ (ពោល គឺចំនួន១,៩ភាគរយ នៅប្រទេសបង់ក្លាដេស ចំនួន២,២ភាគរយនៅប្រទេសចិន និងចំនួន១,៦ភាគរយនៅប្រទេសស្រីលង្កា)[29]។
- ការសិក្សាស្រាវជ្រាវមួយផ្សេងទៀត បានរកឃើញថាចំនួន៩០ភាគរយនៃស្ត្រីដែលពាក់ព័ន្ធក្នុងសេវាផ្លូវភេទចំនួន៣៣នាក់ ដែលបានធ្វើសម្ភាសន៍ បាននិយាយថាពួកគេត្រូវបានរំលោភសេពសន្ថវៈកាលពីឆ្នាំមុន ហើយភាគច្រើននៃអំពើរំលោភសេពសន្ថវៈនោះ គឺជាការរំលោភបូក។ លើសពីនេះទៅទៀត ចំនួន២០ភាគរយនៃពួកគេត្រូវបានរំលោភសេពសន្ថវៈ មុនពេលបានចូលពាក់ព័ន្ធក្នុង សេវាផ្លូវភេទ[30]។

## ស្ថានភាពសេដ្ឋកិច្ចទាប និងកង្វះឱកាសការងារ៖

ជារឿយៗ ស្ត្រីដែលមកពីក្រុមងាយរងគ្រោះទំនងជាកាន់តែធ្លាក់ខ្លួនក្រ ឬមានប្រាក់ចំណូល កាន់តែតិចជាងស្ត្រី និងបុរសផ្សេងទៀត រាប់ទាំងបុរសដែលមកពីក្រុមងាយរងគ្រោះដូចគ្នា។ ការងារ និងសកម្មភាពសេដ្ឋកិច្ចដែលទទួលបានប្រាក់ចំណូលសមរម្យ គឺមានសារៈសំខាន់នៅក្នុងការលើកកម្ពស់ភាពអង់អាចផ្នែកសេដ្ឋកិច្ចរបស់ក្រុមស្ត្រីទាំងនោះ និងធ្វើឱ្យប្រសើរឡើងនូវលទ្ធភាពរបស់ពួកគេនៅក្នុងការទទួលបានសេវាសាធារណៈប្រកបដោយគុណភាព។ ម្យ៉ាងទៀតការពឹងផ្អែកផ្នែកសេដ្ឋកិច្ចទៅលើបុរសជាដៃគូ អាចជាឧបសគ្គមួយបន្ថែមទៀត ចំពោះស្ត្រីដែលចង់គេចខ្លួនចេញពីអំពើហិង្សាពីសំណាក់ដៃគូស្និទ្ធស្នាលរបស់ខ្លួន។

29 Fulu, Warner, Miedema, Jewkes, Roselli&Lang, អង្គការដៃគូសម្រាប់ការទប់ស្កាត់ ឆ្នាំ២០១៣។

30 Jenkins, C, អំពើហិង្សា និងការប្រឈមនឹងការឆ្លងមេរោគអេដស៍ ក្នុងចំណោមស្ត្រីពាក់ព័ន្ធក្នុងសេវាផ្លូវភេទ នៅក្នុងរាជធានីភ្នំពេញ សហជីពស្ត្រីពាក់ព័ន្ធក្នុងសេវាផ្លូវភេទកម្ពុជា បណ្តាញស្ត្រីដើម្បីសាមគ្គីភាព Candice Sainsbury ឆ្នាំ២០០៦។

## ស្ត្រីពិការ៖

- អត្រាសកម្មភាពសេដ្ឋកិច្ចសម្រាប់ប្រជាពលរដ្ឋពិការ ដែលមានអាយុចន្លោះពី១៥ដល់៦៤ឆ្នាំ (ចំនួន៦៩,២៩ភាគរយ) មានកម្រិតទាបជាងអត្រាសកម្មភាពសេដ្ឋកិច្ចរបស់ប្រជាពលរដ្ឋទូទៅ (ចំនួន៨២,២ភាគរយ)។ ខណៈដែលអត្រាសកម្មភាពសេដ្ឋកិច្ចរបស់បុរសពិការវិញមានពិន្ទុទាប ជាង៨,៣៦ពិន្ទុ។ រីឯអត្រាសកម្មភាពសេដ្ឋកិច្ចរបស់ស្ត្រីពិការ មានពិន្ទុទាបជាងរហូត ដល់ទៅ១៩,៣៧ពិន្ទុ[31] ។
- គម្លាតរវាងអត្រាសកម្មភាពសេដ្ឋកិច្ចរបស់បុរស (ចំនួន៧៦,១៧ភាគរយ) និងស្ត្រី (ចំនួន៦០,៦២ភាគរយ) ក្នុងចំណោមប្រជាពលរដ្ឋពិការ គឺមានកម្រិតខ្ពស់ជាងគម្លាតរវាងកម្រិតទាំងពីរខាងលើ ក្នុងចំណោមប្រជាពលរដ្ឋទូទៅ ពោលគឺ (ចំនួន៨៤,៥ភាគរយសម្រាប់បុរស និង៨០ភាគរយសម្រាប់ស្ត្រី)[32] ។
- ទ្រព្យសម្បត្តិគ្រួសាររបស់ជនពិការ គឺមានចំនួនប្រហែលពាក់កណ្តាលនៃទ្រព្យសម្បត្តិគ្រួសាររបស់ជនមិនមានពិការភាព[33]។
- ៣៨,៥ភាគរយនៃជនពិការ នៅប្រទេសកម្ពុជា អាចរកប្រាក់ចំណូលបាន ប៉ុន្តែ ៤២,៦ភាគរយមិនអាចរកប្រាក់ចំណូលបានទេ ហើយ១៨,៨ភាគរយ មានអាយុក្រោម១៨ឆ្នាំ។ ចំនួនភាគរយនៃស្ត្រីពិការដែលអាចរកប្រាក់ចំណូលបាន គឺមានចំនួនតិចជាងច្រើន បើប្រៀបធៀបទៅនឹងបុរសពិការ (ចំនួន២៥,៨ភាគរយទល់នឹងចំនួន៤៤,៨ភាគរយ)[34]។

## ស្ត្រីវ័យចំណាស់៖

- ស្ត្រីដែលមានអាយុពី៥៥ ទៅ៦៤ឆ្នាំ មានអត្រាចូលរួមក្នុងកម្លាំងពលកម្មទាបបើប្រៀបធៀបទៅនឹងបុរស ដែលមានអាយុដូចគ្នា (ចំនួន ៦៥,៣ភាគរយទល់នឹងចំនួន៨៩,១ភាគរយ)[35] ។

---

[31] អង្កេតចន្លោះជំរឿននៃប្រជាសាស្ត្រកម្ពុជា ២០១៣ ក្រសួងផែនការ

[32] អង្កេតចន្លោះជំរឿននៃប្រជាសាស្ត្រកម្ពុជា ២០១៣ ក្រសួងផែនការ

[33] MRTC, ឆ្នាំ២០០៩ ពីឯកសារសង្ខេប៖ ការពិតអំពីពិការភាពនៅកម្ពុជា អង្គការជនពិការអន្តរជាតិ ខែមិនា ឆ្នាំ២០១៣។

[34] ទិន្នន័យមូលដ្ឋានឃុំ សង្កាត់ ឆ្នាំ២០០៨ របស់ក្រសួងផែនការ ការថែរក្សាសុខភាពសម្រាប់ក្រុមដែលងាយរងគ្រោះនៅកម្ពុជា អង្គការ GIZ ខែវិច្ឆិកា ឆ្នាំ២០១០។

[35] អង្កេតសេដ្ឋកិច្ច និងសង្គមកិច្ចកម្ពុជា ២០១២




▲ ស្ត្រីដែលស្រឡាញ់ភេទដូចគ្នា រងនូវការរើសអើង និងហិង្សា

- មានគម្លាតយេនឌ័រដ៏ខ្លាំងមួយ នៅក្នុងភាគរយនៃប្រជាជនដែលមានកម្លាំងពលកម្មការងារ ដែលមានអាយុពី៥៥ ទៅ៦៤ឆ្នាំ ដែលមិនបានទទួលការអប់រំ ឬមានការអប់រំខ្លះ៖ ស្ត្រីមានចំនួន៣៥,៨ភាគរយ បើប្រៀបធៀបទៅនឹងបុរសចំនួន១៤ភាគរយ[36] ។

- នៅប្រទេសកម្ពុជា មនុស្សវ័យចំណាស់មានការលំបាកក្នុងការសន្សំប្រាក់នៅក្នុងជីវិតការងាររបស់ខ្លួន។ ជាលទ្ធផល ពួកគាត់មានវ័យកាន់តែចាស់នៅក្នុងសភាពមួយដែលងាយរងគ្រោះខាងផ្នែកសម្ភារៈ និងផ្លូវកាយ។ ការកើនឡើងនូវចំនួនមនុស្សចាស់ដែលជាអ្នកមើលថែទាំចៅៗ គឺដោយសារតែកូនវ័យជំទង់របស់គាត់ត្រូវធ្វើចំណាកស្រុក ឬក៏ឪពុកម្តាយលែងលះគ្នា និងស្លាប់ជាដើម[37]។

[36] អង្កេតសេដ្ឋកិច្ច និងសង្គមកិច្ចកម្ពុជា ២០១២

[37] មនុស្សចាស់ និងទេសន្តរប្រវេសន៍នៅកម្ពុជា៖ របាយការណ៍ CRUMP Series ក្រសួងផែនការកម្ពុជា និងអង្គការ UNFPA ឆ្នាំ២០១៣ ពីការធ្វើវិភាគទៅលើយេនឌ័រ និងបញ្ហាលេចឡើង ដោយផ្តោតទៅលើមនុស្សចាស់ អង្គការ HelpAge កម្ពុជា ឆ្នាំ២០១៤។

## ស្ត្រីមេម៉ាយ និងស្ត្រីជាមេគ្រួសារ៖

- ស្ត្រីជាមេគ្រួសារម្នាក់មានដីជាមធ្យម តិចជាងបុរសម្នាក់ដែលជាមេគ្រួសារចំនួន ៥៥ភាគរយ។ ខណៈដែលស្ត្រីជាមេគ្រួសារនៅកម្ពុជាមានចំនួន២២ភាគរយ ពួកគេមានដីសម្រាប់ធ្វើកសិកម្មចំនួន១២ភាគរយតែប៉ុណ្ណោះ (៨០៣.០០០ហិកតា) [38] ។

- ស្ត្រីជាមេគ្រួសារ មានសមាជិកគ្រួសារដែលមិនសកម្មផ្នែកសេដ្ឋកិច្ចច្រើនជាងបុរសជាមេគ្រួសារ។ ស្ត្រីជាមេគ្រួសារចំនួន៤,៩៦ភាគរយ មិនមានសមាជិកគ្រួសារដែលសកម្មផ្នែកសេដ្ឋកិច្ច បើប្រៀបធៀបទៅនឹងបុរសជាមេគ្រួសារដែលមានចំនួន១,៣ ភាគរយ[39] ។

## ស្ត្រីដែលមកពីក្រុមជនជាតិដើមភាគតិច៖

- មិនទាន់មានទិន្នន័យជាក់លាក់ណាមួយ ស្តីពីស្ថានភាពរបស់ស្ត្រីជនជាតិដើមភាគតិចនៅក្នុងប្រទេសកម្ពុជានៅឡើយទេ។ បញ្ហាប្រឈមចំពោះមុខរបស់សហគមន៍ជនជាតិដើមភាគតិចនៅក្នុងប្រទេសកម្ពុជា គឺការបាត់បង់សិទ្ធិកាន់កាប់ដីធ្លី និងធនធានធម្មជាតិ។ ការផ្ទេរកម្មសិទ្ធិកាន់កាប់ដីធ្លីបានបណ្តាលឱ្យមានការបាត់បង់ការងារ ដែលធ្វើឱ្យមុខរបរចិញ្ចឹមជីវិត និងសុខភាពកាន់តែដុនដាបទៅៗ ការបាត់បង់ឱកាសចូលរៀន និងការបាត់បង់ការប្រតិបត្តិប្រពៃណី និងវប្បធម៌។ ភាពក្រីក្ររបស់សហគមន៍ជនជាតិដើមភាគតិចមានជាប់ពាក់ព័ន្ធនឹងការខ្វះខាតនូវតំណាងរបស់ជនជាតិដើមភាគតិចនៅក្នុងការធ្វើសេចក្តីសម្រេច និងការបង្កើតនិងការអនុវត្តន៍គោលនយោបាយ និងច្បាប់នានាផងដែរ[40]។

## ហានិភ័យដ៏ខ្ពស់នៃការទទួលរងគ្រោះ ដោយសារសុខភាពទន់ខ្សោយ៖

ស្ត្រី និងក្មេងស្រីដែលមកពីក្រុមងាយរងគ្រោះ ទំនងជាទទួលរងគ្រោះដោយសារសុខភាពផ្លូវចិត្ត និងផ្លូវកាយកាន់តែទន់ខ្សោយ រួមទាំងជំងឺធ្លាក់ទឹកចិត្ត ជំងឺបាក់ស្បាត ការឆ្លងមេរោគអេដស៍ និងជំងឺផ្សេងៗទៀតដែលពាក់ព័ន្ធនឹងកង្វះអាហារូបត្ថម្ភ និងការតានតឹងចិត្ត។ កង្វះលទ្ធភាពទទួលបានសេវាសុខភាព ឬសេវាសុខភាពដែលមិនមាន

[38] អង្កេតសេដ្ឋកិច្ច និងសង្គមកិច្ចកម្ពុជា ២០១២

[39] អង្កេតសេដ្ឋកិច្ច និងសង្គមកិច្ចកម្ពុជា ២០១២

[40] កំណត់សម្គាល់ផ្នែកបច្ចេកទេសចំពោះប្រទេសកម្ពុជា ស្តីពីបញ្ហារបស់ជនជាតិដើមភាគតិច IFAD ឆ្នាំ២០១២។

ការឆ្លើយតប អាចបណ្តាលឱ្យមាន ឬធ្វើឱ្យបញ្ហាសុខភាពមាន សភាពកាន់តែធ្ងន់ធ្ងរ និងរួមចំណែកធ្វើឱ្យមានពិការភាព។

## ស្ត្រីពិការ៖

- ស្ត្រីពិការមានតម្រូវការថែទាំសុខភាពលើសពីកម្រិតមធ្យម ដែលប្រើប្រាស់សេវារបស់អ្នកជំនាញឯកទេសកាន់តែច្រើន និងការចំណាយទៅលើសេវាសុខភាពកាន់តែខ្ពស់ បើប្រៀបធៀបទៅនឹងស្ត្រីដែលមិនពិការ។ ការចំណាយទៅលើសេវាសុខភាពរបស់ពួកគេ មានសមាមាត្រកាន់តែខ្ពស់ជាងប្រាក់ចំណូលរបស់ពួកគេ បើប្រៀបធៀបទៅនឹងស្ត្រីដែលមិនពិការ[41] ។
- ស្ត្រីពិការអាចជួបប្រទះភាពមួហ្មងក្នុងចិត្តក្នុងកម្រិតកាន់តែខ្ពស់ជាងស្ត្រីផ្សេងៗទៀត[42] ។

## ស្ត្រីវ័យចំណាស់៖

- ខណៈដែលអត្រាប្រេវ៉ាឡង់នៃជំងឺរ៉ាំរ៉ៃ ដូចជាជំងឺទឹកនោមផ្អែម និងជំងឺលើសឈាមជាដើម មានកម្រិតកាន់តែខ្ពស់ចំពោះមនុស្សវ័យចំណាស់ តម្រូវការសេវាសុខភាពប្រកបដោយគុណភាពកាន់តែមានកម្រិតខ្ពស់សម្រាប់ស្ត្រី និងបុរសវ័យចំណាស់ ដោយសារតែសុខភាពរបស់ពួកគាត់កាន់តែទន់ខ្សោយ[43]។
- បើទោះបីជាភាពចាស់ជរាអាចជាលក្ខណៈវិជ្ជមានសម្រាប់ស្ត្រី ដោយសារតែអាយុសង្ឃឹមរស់របស់ពួកគាត់មានកម្រិតវែងក៏ដោយ ក៏ជារឿយៗ ភាពចាស់ជរានេះមានន័យថាពួកគាត់កាន់តែមានភាពឯកោឆ្ងាយពីសង្គមកាន់តែមានភាពលំបាកផ្នែកសេដ្ឋកិច្ច និងកាន់តែមានហានិភ័យកាន់តែខ្ពស់នៅក្នុងដំណាក់កាលទីបញ្ចប់នៃជីវិតរស់នៅជាមួយនឹងភាពទ្រុឌទ្រោម និងពិការភាពផងដែរ[44] ។

---

41 អង្គការសុខភាពពិភពលោក ឆ្នាំ២០១២ គម្រោងគាំពារសុខភាពសង្គមនៃអង្គការ GIZ ខែកុម្ភៈ ឆ្នាំ២០១៣

42 ទណ្ឌកម្មត្រីគុណ៖ AusAID ឆ្នាំ២០១៣ Astbury, Jill and Fareen Walji (2013) *Triple Jeopardy: Gender-based violence and human rights violations experienced by women with disabilities in Cambodia.*

43 ព័ត៌មានបច្ចុប្បន្នភាពស្ដីពីក្រុមដែលងាយរងគ្រោះ គម្រោងគាំពារសុខភាពសង្គមនៃអង្គការ GIZ ខែកុម្ភៈ ឆ្នាំ២០១៣។

44 *Gender and Emerging Issues with Focus on Ageing Population* អង្គការ HelpAge កម្ពុជា ឆ្នាំ២០១៤

## ស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ និងក្រុមមនុស្សកែភេទ៖

- នៅប្រទេសកម្ពុជា ទោះបីជាមានការខ្វះខាតនូវប្រព័ន្ធទិន្នន័យជាក់លាក់អំពីក្រុមស្ត្រីស្រឡាញ់ស្ត្រី ក្រុមស្ត្រីស្រឡាញ់ទាំងពីរភេទ និងក្រុមមនុស្សកែភេទក៏ដោយ ក៏ការសិក្សាស្រាវជ្រាវនានានៅក្នុងពិភពលោកបានលើកឡើងថា ក្រុមស្ត្រីស្រឡាញ់ស្ត្រី ក្រុមស្ត្រីស្រឡាញ់ទាំងពីរភេទ និងក្រុមមនុស្សកែភេទទំនងជាប្រឈមនឹងបញ្ហាសុខភាពផ្លូវចិត្ត និងការធ្វើអត្តឃាតកាន់តែច្រើនឡើងដែលជារឿយៗបានកើតឡើងបន្ទាប់ពីបានទទួលរងគ្រោះដោយសារការសម្លុតគំរាមកំហែង ការរំលោភបំពានជាពាក្យសម្ដី ការនៅឯកោឆ្ងាយពីសង្គម និងការរំពឹងទុកថានឹងបានរួមរស់ជាមួយគ្រួសារ និងការជ្រកក្រោមប្រពៃណីវប្បធម៌ឡើងវិញ អស់រយៈពេលជាច្រើនឆ្នាំមកហើយ[45]។

## ស្ត្រីដែលធ្លាប់ទទួលរងគ្រោះដោយសារអំពើហិង្សាផ្លូវភេទនិងឬការរៀបការដោយបង្ខំក្នុងអំឡុងរបបខ្មែរក្រហម៖

- ការសិក្សាស្រាវជ្រាវ[46] ដែលបានធ្វើជាមួយស្ត្រីទទួលរងគ្រោះដោយសារអំពើហិង្សាផ្លូវភេទក្នុងអំឡុងរបបខ្មែរក្រហមបានបង្ហាញថា ភាគច្រើននៃស្ត្រីទទួលរងគ្រោះទាំងនោះជួបប្រទះផលប៉ះពាល់ដែលនៅតែកើតមានជាបន្ត ដូចជាការប៉ះទង្គិចផ្លូវចិត្តដ៏ធ្ងន់ធ្ងរ ការឈឺចាប់ផ្លូវចិត្តដោយសារអំពើរំលោភសេពន្ទវៈ រួមទាំងការមានកំហឹង ជំងឺធ្លាក់ទឹកចិត្ត ការយល់សប្តិអាក្រក់ ការគិតអំពីការធ្វើអត្តឃាត ការគេងមិនលក់ និងការមានអារម្មណ៍វិលវល់ជាដើម។ បញ្ហាសុខភាពបន្តពូជ ផ្លូវកាយដូចជាការឈឺចាប់ប្រដាប់បន្តពូជឬការធ្លាក់ឈាមនិងផលប៉ះពាល់សុខភាពផ្លូវកាយរួមទាំងការនៅបន្តរងរបួស ការឈឺចាប់ ឬពិការភាពផ្លូវកាយ (ឧទាហរណ៍៖ ការលំបាកដើរ) ការជ្រួលច្របល់ផ្លូវចិត្ត និងការទទួលបន្ទុកផ្នែកហិរញ្ញវត្ថុលើការចិញ្ចឹម

---

45 ឥន្ទធនូខ្មែរៈ ប្រែការរើសអើង ទៅជាមោទនភាព មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ឆ្នាំ២០១២ *Rainbow Khmer: From Prejudice to Pride* ។

46 Nakagawa, k, អំពើហិង្សាទាក់ទងនឹងយេនឌ័រនៅក្នុងរបបខ្មែរក្រហម។ រឿងរ៉ាវនានារបស់អ្នកនៅរស់រានមានជីវិតពីរបបកម្ពុជា ប្រជាធិបតេយ្យ (ឆ្នាំ១៩៧៥-១៩៧៩) រាជធានីភ្នំពេញៈ ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា ឆ្នាំ២០០៨, Natale, k,“ខ្ញុំមានអារម្មណ៍ថាព្រលឹងរបស់ខ្ញុំហោះចេញពីខ្លួនខ្ញុំ” ការសិក្សាស្រាវជ្រាវមួយអំពីអំពើហិង្សាទាក់ទងនឹងយេនឌ័រក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យនៅខេត្តបាត់ដំបង និងខេត្តស្វាយរៀង (រាជធានីភ្នំពេញ ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា ឆ្នាំ២០១១), Rochelle Braaf, អំពើហិង្សាផ្លូវភេទលើជនជាតិភាគតិច ក្នុងអំឡុងរបបខ្មែរក្រហម (រាជធានីភ្នំពេញ ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា ឆ្នាំ២០១៤)។

កូនដែលជាលទ្ធផលនៃអំពើរំលោភសេពសន្ថវៈការលំបាកនៅក្នុងការធ្វើទំនាក់ទំនងជាធម្មតាជាមួយដៃគូ និងស្លាកស្នាមរងគ្រោះក្នុងសង្គមនិងការផាត់ចេញពីការចូលរួមធ្វើសកម្មភាពនៅក្នុងសហគមន៍របស់ខ្លួនជាដើម។

- ការសិក្សាស្រាវជ្រាវ[47]ដែលបានធ្វើជាមួយស្ត្រីទទួលរងគ្រោះដោយសារការរៀបការដោយបង្ខំក្នុងអំឡុងរបបខ្មែរក្រហម បានបង្ហាញថាភាគច្រើននៃស្ត្រីទទួលរងគ្រោះទាំងនោះ កំពុងតែរស់នៅជាមួយនឹងការប៉ះទង្គិចផ្នែកចិត្តសាស្ត្រ និង ឬផ្លូវកាយដោយសារតែការបង្ខិតបង្ខំឱ្យរៀបការជាមួយស្វាមីក្រោយរបស់ខ្លួនពីសំណាក់ពួកខ្មែរក្រហម។

## ស្ត្រី ដែលពាក់ព័ន្ធក្នុងសេវាផ្លូវភេទ៖

- ស្ត្រីដែលពាក់ព័ន្ធក្នុងសេវាផ្លូវភេទ ជាទូទៅមានតម្រូវការកាន់តែកើនឡើង នៅក្នុងការទទួលបានសេវាសុខភាពបន្តពូជ និងសេវាសុខភាពផ្លូវភេទ ដោយគ្មានការរើសអើងដោយសារតែមានអត្រានៃការពន្លូតកូន តម្រូវការពន្យារកំណើតដែលមិនបានឆ្លើយតប និងការប្រឈមនឹងការឆ្លងមេរោគអេដស៍ និងជំងឺកាមរោគដទៃទៀតកាន់តែមានកម្រិតខ្ពស់។ ឧទាហរណ៍ស្ត្រីដែលពាក់ព័ន្ធក្នុងសេវាផ្លូវភេទចំនួន៣៧,៨ភាគរយនៃស្ត្រីដែលពាក់ព័ន្ធក្នុងសេវាផ្លូវភេទចំនួន១.២៤៦នាក់ដែលបានធ្វើសម្ភាសន៍សម្រាប់ការអង្កេតតាមដានចំណេះដឹង ស្តីពីជំងឺអេដស៍ និងការប្រព្រឹត្តិផ្លូវភេទ ឆ្នាំ២០១៣ បានរាយការណ៍អំពីរោគសញ្ញានៃការឆ្លងកាមរោគ កាលពីឆ្នាំមុន[48]។

## ឧបសគ្គកាន់តែច្រើនក្នុងការទទួលបានធនធានសាធារណៈ ដូចជាសេវាសុខភាព អប់រំ និងយុត្តិធម៌៖

- សេវាសាធារណៈមិនមែនសុទ្ធតែបានបំពេញទៅតាមតម្រូវការរបស់ស្ត្រីដែលមកពីក្រុមងាយរងគ្រោះឡើយ។ ពេលខ្លះក្រុមស្ត្រីងាយរងគ្រោះមិនអាចទទួលបានសេវាសាធារណៈដោយសារតែភាពក្រីក្ររបស់ពួកគាត់មានកម្រិតខ្ពស់ កន្លែងផ្តល់សេវា

[47] Rochelle Braaf, អំពើហិង្សាផ្លូវភេទលើជនជាតិភាគតិច ក្នុងអំឡុងរបបខ្មែរក្រហម (រាជធានីភ្នំពេញ ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា ឆ្នាំ ២០១៤), Theresa De Langis, “ដូចខ្មោចដូររូប” ការសិក្សាស្រាវជ្រាវមួយ អំពីផលប៉ះពាល់នៃការរៀបការដោយបង្ខំ ក្នុងអំឡុងរបបខ្មែរក្រហម (រាជធានីភ្នំពេញ អង្គការចិត្តសង្គម អន្តរវប្បធម៌ ដែលជិតមកដល់)។

[48] ការអង្កេតតាមដានចំណេះដឹងស្តីពីជំងឺអេដស៍ និងការប្រព្រឹត្តិផ្លូវភេទ ឆ្នាំ២០១៣ មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍សើស្បែក និងកាមរោគ ក្រសួងសុខាភិបាល ឆ្នាំ២០១៣។

មានទីតាំងនៅឆ្ងាយពីផ្ទះរបស់អតិថិជន ហេដ្ឋារចនាសម្ព័ន្ធមិនសមស្រប ឬការខ្វះខាតសមត្ថភាព និងការយល់ដឹងរបស់អ្នកផ្តល់សេវាមានកម្រិត។ ជាលទ្ធផល ស្ត្រី និងក្មេងស្រីដែលមកពីក្រុមងាយរងគ្រោះមានឱកាសតិចតួចនៅក្នុងការទទួលបានសេវាអប់រំ យុត្តិធម៌ និងសេវាសុខភាពផ្លូវភេទនិងសុខភាពបន្តពូជដែលមានគុណភាព។ ករណីបែបនេះ កើតមានជាពិសេសចំពោះស្ត្រីនិងក្មេងស្រីពិការ ស្ត្រីនិងក្មេងស្រីដែលរស់នៅតំបន់ដាច់ស្រយាល ស្ត្រីនិងក្មេងស្រីដែលមកក្រុមស្ត្រីស្រឡាញ់ស្ត្រី ក្រុមមនុស្សស្រឡាញ់ទាំងពីរភេទ និងក្រុមមនុស្សកែភេទ និងស្ត្រីនិងក្មេងស្រីដែលទទួលរងគ្រោះដោយសារអំពើហិង្សាទាក់ទងនឹងយេនឌ័រ។ ការយល់ដឹង ការយកចិត្តទុកដាក់ចំពោះយេនឌ័រ និងចំណេះដឹងរបស់មន្ត្រីរាជការរួមមានបុគ្គលិកសុខាភិបាល គ្រូបង្រៀន ភ្នាក់ងារសន្តិសុខ នគរបាល ចៅក្រម និងអ្នកផ្តល់សេវាផ្នែកច្បាប់ជាដើម គឺជាកត្តាដ៏សំខាន់ ដែលធ្វើឱ្យសេវាសាធារណៈកាន់តែឆ្លើយតបទៅនឹងតម្រូវការរបស់ស្ត្រីដែលមកពីក្រុមងាយរងគ្រោះ។

## ស្ត្រីពិការ៖

- អត្រាចេះអាន និងសរសេរអក្សររបស់ជនពិការ នៅក្នុងឆ្នាំ២០១៣ មានចំនួន៥៧,៩ភាគរយ ដែលជាកម្រិតទាបជាងប្រជាពលរដ្ឋទូទៅ (៧៩,៨ភាគរយ)។ អត្រាចេះអាន និងសរសេរអក្សរនៅក្នុងចំណោមបុរសពិការ មានចំនួន៦៩,១ភាគរយ ដែលជាកម្រិតទាបជាងយ៉ាងខ្លាំង បើប្រៀបធៀបនឹងអត្រាចេះអាន និងសរសេរអក្សររបស់បុរស នៅក្នុងចំណោមប្រជាពលរដ្ឋទូទៅ (៨៥,១ភាគរយ)។ ចំណែកឯស្ត្រីវិញ អត្រាចេះអាន និងសរសេរអក្សររបស់ស្ត្រីពិការមានចំនួន៤៥,៥ភាគរយ ដែលជាកម្រិតទាបជាងស្ត្រីនៅក្នុងចំណោមប្រជាពលរដ្ឋទូទៅឆ្ងាយណាស់ (៧៤,៨ភាគរយ)[49] ។

- ការសិក្សាស្រាវជ្រាវថ្នាក់តំបន់ និងការសិក្សាស្រាវជ្រាវលើករណីតូចៗមួយចំនួនក្នុងប្រទេសកម្ពុជា បានបង្ហាញថាកុមារពិការមានអត្រាបោះបង់ការសិក្សាខ្ពស់ជាងកុមារមិនពិការ និងមានអត្រាចុះឈ្មោះចូលរៀនទាបជាងកុមារមិនពិការ (UNESCAP ឆ្នាំ២០១២ និងអង្គការជនពិការអន្តរជាតិ ឆ្នាំ២០០៩)[50]។

---

49 អង្កេតចន្លោះជំរឿន នៃប្រជាសាស្ត្រកម្ពុជា ២០១៣

50 UNESCAP (2012), *Disability, Livelihood and Poverty in Asia and the Pacific*, Bangkok, Thailand; and Handicap International (2009), *Briefing Paper: Disability Facts in Cambodia*, Phnom Penh, Cambodia

- មានតែជនពិការកម្ពុជា ២៧ភាគរយតែប៉ុណ្ណោះ ដែលអាចទទួលបានសេវាថែទាំសុខភាពនៅពេលដែលពួកគេមានជំងឺ បើប្រៀបធៀបទៅនឹងប្រជាពលរដ្ឋដែលមិនពិការ មានដល់ទៅ៥៧ភាគរយ។ ជារឿយៗ ប្រការនេះកើតមានឡើងដោយសារតែបញ្ហាលទ្ធភាពនៃការទទួលបានសេវា និងឧបសគ្គផ្នែកសង្គមសេដ្ឋកិច្ច[51]។

## ស្ត្រីវ័យចំណាស់៖

- អត្រាមិនចេះអក្សររបស់ប្រជាជនកម្ពុជាដែលមានអាយុច្រើនជាង៦០ឆ្នាំ មានចំនួន ៥៣,៧ភាគរយ។ មានគម្លាតយេនឌ័រយ៉ាងខ្លាំង ដោយអត្រាស្ត្រីមិនចេះអក្សរមានចំនួនដល់ទៅ៧៣,១ភាគរយ រីឯអត្រាបុរសមិនចេះអក្សរវិញមានចំនួន២៦,១ភាគរយតែប៉ុណ្ណោះ[52] ។

- ប្រព័ន្ធសន្តិសុខសង្គមនៅក្នុងប្រទេសកម្ពុជានៅមានកម្រិតនៅឡើយ ហើយការជួយគាំទ្រពីគ្រួសារនៅតែជាសំណាញ់សុវត្ថិភាពជាបឋមសម្រាប់មនុស្សចាស់។ មនុស្សធំពេញវ័យមានកាតព្វកិច្ច ក្នុងនាមជាកូនស្រី និងកូនប្រុសក្នុងការផ្គត់ផ្គង់ និងមើលថែទាំឪពុកម្ដាយដែលចាស់ជរា។ ទោះជាយ៉ាងណាក៏ដោយ ប្រព័ន្ធជួយគាំទ្រថែទាំមនុស្សចាស់តាមលក្ខណៈគ្រួសារបែបនេះបានទទួលរងសម្ពាធ ហើយគេរំពឹងទុកថានឹងមានលក្ខណៈកាន់តែយាប់យឺនទៅៗ ដោយសារតែពេលវេលាការប្រែប្រួលដ៏លឿនពីស្ថានភាពជនបទទៅជាទីក្រុង ការធ្វើចំណាកស្រុកនៃកម្លាំងពលកម្ម ការកើនឡើងនូវការចូលរួមរបស់ស្ត្រីវ័យចំណាស់ក្នុងការងារដែលមានកម្រៃ និងការផ្លាស់ប្ដូររចនាសម្ព័ន្ធក្នុងគ្រួសារ[53]។

## ស្ត្រីស្រឡាញ់ស្ត្រី និងក្រុមមនុស្សកែភេទ៖

- ទោះបីជាពុំមានទិន្នន័យជាក់លាក់នៅក្នុងប្រទេសកម្ពុជានៅឡើយក៏ដោយ ក៏ការសម្លុតគំរាមកំហែងទៅលើសិស្សស្រីដែលមកពីក្រុមស្ត្រីស្រឡាញ់ស្ត្រី និងក្រុមមនុស្សកែភេទ គឺជាបញ្ហាដ៏ធ្ងន់ធ្ងរមួយជាសកល និងជាការគំរាមកំហែងមួយចំពោះសិទ្ធិមូលដ្ឋានជាសកល នៅក្នុងការទទួលបានការអប់រំ។ ការសម្លុតគំរាមកំហែងមិន

[51] ADD ឆ្នាំ២០០៧ គម្រោងគាំពារសុខភាពសង្គមនៃអង្គការ GIZ ខែកុម្ភៈ ឆ្នាំ២០១៣។

[52] អង្កេតសេដ្ឋកិច្ច និងសង្គមកិច្ចកម្ពុជា ២០១២ វិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ

[53] *Gender and Emerging Issues with Focus on Ageing Population* អង្គការ HelpAge កម្ពុជា ឆ្នាំ២០១៤។

ត្រឹមតែធ្វើឱ្យសិស្សឆាប់បោះបង់ការសិក្សាតែប៉ុណ្ណោះនោះទេ ប៉ុន្តែថែមទាំងបានបណ្តាលឱ្យមានជំងឺធ្លាក់ទឹកចិត្ត ការចង់ធ្វើអត្តឃាត និងការប្រកាន់យកឥរិយាបថដែលប្រកបដោយគ្រោះថ្នាក់ខ្ពស់ ដូចជាការប្រើប្រាស់ថ្នាំញៀន និងការរួមភេទដែលមិនមានសុវត្ថិភាព [54]។

[54] ការពិនិត្យមើលឡើងវិញទៅលើការសម្លុតកំហែងយកចំពោះក្រុមមនុស្សស្រឡាញ់ភេទដូចគ្នា នៅក្នុងគ្រឹះស្ថានអប់រំ UNESCO ឆ្នាំ ២០១២ ឥន្ទធនូខ្មែរ: ប្រែការរើសអើង ទៅជាមោទនភាព មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ឆ្នាំ ២០១២។

## អនុសាសន៍សម្រាប់គោលនយោបាយ

| គោលនយោបាយដើម្បីសមភាពយេនឌ័រ និងក្រុមងាយរងគ្រោះ៖ | |
|---|---|
| • ដាក់បញ្ចូលបន្ថែមទៀត និងកាន់តែឆ្លើយតបទៅនឹងតម្រូវការរបស់ក្រុមស្ត្រី និងក្មេងស្រីដែលងាយរងគ្រោះទៅក្នុងគោលនយោបាយ និងកម្មវិធីសមភាពយេនឌ័រ និងការផ្តល់ភាពអង់អាចដល់ស្ត្រី។ នៅក្នុងដំណើរការរៀបចំផែនការយុទ្ធសាស្ត្រនារីរតនៈទី៤ គឺជាឱកាសក្នុងការឆ្លើយតបនឹងតម្រូវការទាំងនេះ ។ | ក្រសួងកិច្ចការនារី |
| • គ្រប់គោលនយោបាយ និងលិខិតបទដ្ឋានទាំងឡាយដែលរៀបចំ ឡើងសម្រាប់ក្រុមងាយរងគ្រោះ ត្រូវពង្រឹងការអនុវត្តឱ្យបានពេញលេញឱ្យមានការឆ្លើយតបនឹងតម្រូវការយេនឌ័រ ដើម្បីដាក់បញ្ចូលនូវតម្រូវការជាក់លាក់របស់ស្ត្រី និងក្មេងស្រី ដែលមកពីក្រុមងាយរងគ្រោះនេះ។ | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងសុខាភិបាល |
| • ធានាថាទិន្នន័យ និងស្ថិតិនានា មានបែងចែកទៅតាមភេទ ក៏ដូចជាបែងចែកទៅតាមប្រភេទនីមួយៗនៃក្រុមងាយរងគ្រោះ ជាពិសេស មានការបញ្ជាក់អំពីស្ថានភាពនៃពិការភាព និងអាយុ។ | ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងកិច្ចការនារី ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ក្រុមប្រឹក្សាសកម្មភាពជនពិការ ក្រសួងអប់រំ យុវជន និងកីឡា វិទ្យាស្ថានជាតិស្ថិតិ (ក្រសួងផែនការ) ក្រសួងមហាផ្ទៃ ក្រសួងយុត្តិធម៌ |

| | |
|---|---|
| • សិក្សាស្រាវជ្រាវបន្ថែមទៀតនូវបញ្ហាប្រឈម និងតម្រូវការនានារបស់ស្ត្រី និងក្មេងស្រីដែលមកពីក្រុមងាយរងគ្រោះ ជាពិសេសស្ត្រីដែលមកពីក្រុមជនជាតិដើមភាគតិច ជនជាតិភាគតិច ស្ត្រីមេម៉ាយ ក្រុមស្ត្រីស្រឡាញ់ស្ត្រី ក្រុមមនុស្សកែភេទ និងស្ត្រីជាប់ពន្ធនាគារ ព្រមទាំងចាត់វិធានការ ក្នុងការបង្កើនការយល់អំពីបញ្ហាទាំងនេះដល់អ្នកពាក់ព័ន្ធ និងដើម្បីជំរុញឲ្យមានការឆ្លើយតបក្នុងគោលនយោបាយ និងកម្មវិធីតាមវិស័យ។ | គ្រប់ស្ថាប័នរាជរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល ក្រសួង និងស្ថាប័នពាក់ព័ន្ធ ក្រសួង និងស្ថាប័នពាក់ព័ន្ធ |
| **ការរើសអើង ស្លាកស្នាមរងគ្រោះអំពើហិង្សា និងអំពើហិង្សាទាក់ទងនឹងយេនឌ័រ៖** | |
| • សម្របសម្រួលការពិនិត្យមើលបទដ្ឋានគតិយុត្តឡើងវិញ រៀបចំ និងផ្សព្វផ្សាយគោលការណ៍ណែនាំ ព្រមទាំងរៀបចំវិធានការអភិវឌ្ឍសមត្ថភាពដល់ប្រតិបត្តិករក្នុងវិស័យយុត្តិធម៌ ដើម្បីកែលម្អកិច្ចការពារផ្លូវច្បាប់ដល់ស្ត្រី និងក្មេងស្រីពិការដែលធ្លាប់ទទួលរង គ្រោះដោយសារអំពើហិង្សាទាក់ទងនឹងយេនឌ័រ និង/ឬអំពើហិង្សាក្នុងគ្រួសារ ក៏ដូចជាស្ត្រីដែលពាក់ព័ន្ធក្នុងសេវាផ្លូវភេទ និង/ឬស្ត្រី ដែលកំពុងធ្វើការក្នុងទីកន្លែងកំសាន្តរបស់បុរសដែលធ្លាប់ទទួល រងគ្រោះដោយសារអំពើហិង្សាទាក់ទងនឹងយេនឌ័រ។ | ក្រសួងកិច្ចការនារី ក្រសួងយុត្តិធម៌ ក្រសួងមហាផ្ទៃ |
| • ផ្តួចផ្តើមឱ្យមានការពិភាក្សាកម្រិតខ្ពស់ជាមួយអ្នកពាក់ព័ន្ធនានា រាប់ទាំងសមាជិកសហគមន៍ នៃក្រុមស្ត្រីស្រឡាញ់ស្ត្រី ក្រុមបុរស ស្រឡាញ់បុរស ក្រុមមនុស្សស្រឡាញ់ទាំងពីរភេទ និងក្រុមមនុស្ស កែភេទ ដើម្បីរៀបចំយុទ្ធសាស្ត្រជាតិសម្រាប់ការលើកកម្ពស់សិទ្ធិ និងបញ្ចប់ភាពរើសអើងទៅលើក្រុមស្ត្រីស្រឡាញ់ស្ត្រី ក្រុមបុរស ស្រឡាញ់បុរស ក្រុមមនុស្សស្រឡាញ់ទាំងពីរភេទ និងក្រុមមនុស្ស កែភេទ។ | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងកិច្ចការនារី |

| | |
|---|---|
| • ធ្វើការសិក្សាស្រាវជ្រាវជាបន្ថែមទៀតស្វែងយល់ពីមូលហេតុដែលជាឫសគល់នៃសេវាផ្លូវភេទ និងសេចក្តីត្រូវការដែលពាក់ព័ន្ធនឹងសេវាផ្លូវភេទ ដើម្បីមានលទ្ធភាពរៀបចំវិធានការប្រកបដោយប្រសិទ្ធភាព ក្នុងការដោះស្រាយឫសគល់នៃបញ្ហា រាប់ទាំងការបង្កើតនូវកម្មវិធីនានា និងអនុវត្តកម្មវិធីទាំងនោះឱ្យមានប្រសិទ្ធភាព ដើម្បីជួយស្ត្រីដែលមានបំណងចាកចេញពីសេវាផ្លូវភេទនេះ ផងដែរ (អនុសាសន៍លេខ២៧ ឆ្នាំ២០១៣ នៃអនុសញ្ញាCEDAW)។ | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>ក្រសួងកិច្ចការនារី និង<br>ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| • ផ្តួចផ្តើមឱ្យមានការពិភាក្សាជាមួយស្ថាប័នពាក់ព័ន្ធ ក្នុងការរៀបចំគោលនយោបាយដ៏ទូលំទូលាយមួយ ដើម្បីដោះស្រាយបញ្ហាពាក់ព័ន្ធនឹងសេវាផ្លូវភេទ និងពិចារណាពីលទ្ធភាពនៃការដាក់ចេញនូវការដាក់ទោសចំពោះអ្នកទិញសេវាផ្លូវភេទ (អនុសាសន៍ លេខ២៧ ឆ្នាំ២០១៣ នៃអនុសញ្ញា CEDAW)។ | ក្រសួងយុត្តិធម៌<br>ក្រសួងមហាផ្ទៃ ក្រសួងកិច្ចការនារី<br>និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន<br>និងយុវនីតិសម្បទា |
| **នយោបាយ និងការធ្វើសេចក្តីសម្រេច៖** | |
| • លើកកម្ពស់ការចូលរួមរបស់ស្ត្រីជាក្រុមងាយរងគ្រោះក្នុងវិស័យនយោបាយ និងការធ្វើសេចក្តីសម្រេច ជាពិសេសស្ត្រីពិការ ស្ត្រីជនជាតិដើមភាគតិច និងស្ត្រីជនជាតិភាគតិច។ | រដ្ឋសភា<br>ក្រសួងយុត្តិធម៌ |
| • លើកកម្ពស់ការចូលរួមរបស់ស្ត្រីដែលមកពីក្រុមងាយរងគ្រោះនៅក្នុងវិស័យមុខងារសាធារណៈ ជាពិសេសស្ត្រីពិការ ស្ត្រីជនជាតិ ដើមភាគតិច និងស្ត្រីជនជាតិភាគតិច។ លើសពីនេះ គឺបង្កើតឱ្យមានចំនួនកូតាសមភាពយេនឌ័រសម្រាប់ក្រុមងាយរងគ្រោះ ដូចជាចំនួនកូតាសមភាពយេនឌ័រក្នុងចំណោមជនពិការ (ឱ្យបានចំនួន ៥០/៥០)។ | ក្រសួងមុខងារសាធារណៈ |

**ការផ្តល់ភាពអង់អាចផ្នែកសេដ្ឋកិច្ច៖**

| | |
|---|---|
| • និយោជក គ្រឹះស្ថានអប់រំ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ត្រូវបានផ្ដល់ការលើកទឹកចិត្ត តាមរយៈគ្រឿងលើកទឹកចិត្តផ្នែកពន្ធដា និងការគាំពារផ្លូវច្បាប់ ដើម្បីផ្ដល់ការងារដល់ស្ត្រីមកពីក្រុមងាយរងគ្រោះ ជាពិសេសស្ត្រីរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ ក្រុមជនជាតិភាគតិច ពិការ មានផ្ទុកមេរោគអេដស៍ ស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ និងក្រុមមនុស្សកែភេទ កូនចៅស្ត្រីមេម៉ាយ និងស្ត្រីជាមេគ្រួសារ។ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ក្រសួងទេសចរណ៍ ក្រសួងពាណិជ្ជកម្ម ក្រសួងយុត្តិធម៌ |
| • ពង្រីក និងកែលំអរសេវាសន្តិសុខសេដ្ឋកិច្ចរបស់ស្ត្រីវ័យចំណាស់ ដោយពង្រឹងកម្មវិធីសោធននិវត្តន៍សង្គមសម្រាប់មនុស្សចាស់។ | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |

**ការអប់រំ៖**

| | |
|---|---|
| • ពង្រីកអាហារូបករណ៍នៅគ្រប់កម្រិតអប់រំ ដល់ក្មេងស្រីដែលមកពីក្រុមងាយរងគ្រោះ ជាពិសេសក្មេងស្រីពិការ ឬក្មេងស្រីកំពុងរស់នៅក្នុងគ្រួសារដែលមានសមាជិកជាជនពិការ កុមារទទួលរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារ អំពើជួញដូរមនុស្ស កុមារនៃស្ត្រីមេម៉ាយ និងដែលមកពីគ្រួសារដែលមានតែឪពុក ឬតែម្ដាយជាមេគ្រួសារ ក្មេងស្រីដែលមកពីក្រុមជនជាតិភាគតិច ក្មេងស្រីដែលកំពុងរស់នៅក្នុងតំបន់ដាច់ស្រយាល និងកុមារដែលមានម្ដាយជាកម្មការិនីរោងចក្រកាត់ដេរ ឬមានម្ដាយទទួលរងគ្រោះដោយសារអំពើហិង្សាពីសំណាក់ដៃគូស្និទ្ធស្នាល ឬមានម្ដាយជាប់ពន្ធនាគារ។ | ក្រសួងអប់រំ យុវជន និងកីឡា |

| | |
|---|---|
| • បញ្ចូលខ្លឹមសារអប់រំជាក់លាក់ទៅក្នុងកម្មវិធីសិក្សារបស់សាលារៀន ដើម្បីឆ្លុះបញ្ចាំងវប្បធម៌សង្គមគ្រប់បែបយ៉ាងរបស់កម្ពុជា និងតថភាពរបស់ស្ត្រី និងក្មេងស្រីដែលមកពីក្រុមងាយរងគ្រោះ ព្រមទាំងបង្កើនការផ្សព្វផ្សាយការយល់ដឹងអំពីការរើសអើង និងសិទ្ធិរបស់ពួកគេ។ | ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងកិច្ចការនារី |
| • បង្កើនការកសាងហេដ្ឋារចនាសម្ព័ន្ធ និងការពង្រាយបុគ្គលិក សិក្សាកាន់តែច្រើនសម្រាប់ការអប់រំកម្រិតបឋមសិក្សានិងមធ្យមសិក្សានៅក្នុងតំបន់ដាច់ស្រយាល និងតំបន់ដែលមានជនជាតិភាគតិចរស់នៅច្រើន និងកុមារដែលមានម្តាយជាប់ពន្ធនាគារ។ | ក្រសួងអប់រំ យុវជន និងកីឡា |
| • កែលម្អការកសាងហេដ្ឋារចនាសម្ព័ន្ធសាលារៀន ដើម្បីឱ្យក្មេងស្រីពិការនិងគ្រូបង្រៀនពិការមានលទ្ធភាពទទួលបានការសិក្សាសមស្រប។ | ក្រសួងអប់រំ យុវជន និងកីឡា |
| **អត្ថប្រយោជន៍សុខភាព និងសង្គម៖** | |
| • បង្កើតពិធីសារ និងបណ្តុះបណ្តាលយ៉ាងសមស្របដល់បុគ្គលិក សុខាភិបាលអំពីរបៀបឆ្លើយតបនឹងស្ត្រី និងក្មេង ស្រីទទួលរងគ្រោះដោយសារអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងស្ត្រីនិងក្មេងស្រីពិការ ជាពិសេសសេវាសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ។ | ក្រសួងសុខាភិបាល ក្រសួងកិច្ចការនារី |

| | |
|---|---|
| • ពង្រីកហេដ្ឋារចនាសម្ព័ន្ធ និងពង្រាយបុគ្គលិកឱ្យកាន់តែច្រើន សម្រាប់វិស័យសុខភាពមូលដ្ឋាន សុខភាពផ្លូវភេទ និងសុខភាពបន្តពូជនៅតាមតំបន់ដាច់ស្រយាល តំបន់ដែលមានជនជាតិដើមភាគតិច និងជនជាតិភាគតិចរស់នៅច្រើន និងនៅតាមពន្ធនាគារ។ | ក្រសួងសុខាភិបាល |
| • ពង្រឹង និងពង្រីកលទ្ធភាពទទួលបានបានសេវាសុខភាពផ្លូវភេទ សេវាសុខភាពបន្តពូជ ក៏ដូចជាសេវាចិត្តសង្គម និងសេវាសុខភាពផ្លូវចិត្តសម្រាប់ស្ត្រី និងក្មេងស្រីពិការ ស្ត្រីវ័យចំណាស់ ស្ត្រីស្រឡាញ់ស្ត្រី និងក្រុមមនុស្សកែភេទ ស្ត្រីទទួលរងគ្រោះដោយសារអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងកូនរបស់ពួកគេ ស្ត្រីដែលធ្លាប់ទទួលរងគ្រោះដោយសារអំពើហិង្សាផ្លូវភេទ និង/ឬការរៀបការដោយបង្ខំក្នុងអំឡុងរបបខ្មែរក្រហម ស្ត្រី និងក្មេងស្រីមានផ្ទុកមេរោគអេដស៍ ស្ត្រីជាប់ពន្ធនាគារ និងស្ត្រីដែលពាក់ព័ន្ធក្នុងសេវាផ្លូវភេទ និង/ឬស្ត្រី ដែលធ្វើការនៅទីកន្លែងកំសាន្តរបស់បុរស។ | ក្រសួងសុខាភិបាល<br>ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| • បង្កើនវិធានការសុវត្ថិភាពសម្រាប់ស្ត្រីមេម៉ាយ និងស្ត្រីវ័យចំណាស់ ដូចជាពង្រីកកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រចំពោះគ្រួសារដែលមានសមាជិកមានអាយុលើសពី៧០ឆ្នាំឡើងទៅ។ | ក្រសួងមហាផ្ទៃ<br>ក្រសួងផែនការ<br>ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនិតិសម្បទា។ |

# សេចក្តីថ្លែងអំណរគុណ

ការប៉ាន់ប្រមាណយេនឌ័រនៅកម្ពុជាត្រូវបានចងក្រងឡើងនៅក្រោមការដឹកនាំ និងសម្របសម្រួលដោយក្រសួងកិច្ចការនារី ដោយមានការគាំទ្រនិងរួមចំណែកពីក្រសួង ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ និងសង្គមស៊ីវិល។ ក្រសួងកិច្ចការនារីសូមថ្លែងអំណរគុណ ជូនចំពោះលោកជំទាវ ឯកឧត្តម លោក លោកស្រី ដែលបានចូលរួមចំណែកក្នុងការរៀបចំ ឯកសារនេះ ដូចតទៅ៖

**ក្រុមការងាររៀបចំការប៉ាន់ប្រមាណយេនឌ័រនៅកម្ពុជា** ទទួលខុសត្រូវលើដំណើរការ រៀបចំឯកសារទាំងមូល ក្រោមការដឹកនាំរបស់ លោកជំទាវ វេជ្ជបណ្ឌិត អ៊ឹង កន្ថាផាវី រដ្ឋមន្ត្រីក្រសួងកិច្ចការនារី ។ ក្រុមការងារមានលោកជំទាវ ឃឹម ចំរើន រដ្ឋលេខាធិការ ជាប្រធាន និងគាំទ្របច្ចេកទេសដោយផ្ទាល់ពីលោកជំទាវ កេត សំអាត ទីប្រឹក្សាជាន់ខ្ពស់ ក្រសួងកិច្ចការនារី លោកជំទាវ គឹម ស៊ីផាត់ អគ្គនាយិកា ក្រសួងកិច្ចការនារី និង លោក ថេ ឈុនហាក់អគ្គនាយករងក្រសួងកិច្ចការនារីលោកស្រី ញាណ សុចិត្រា ប្រធាននាយកដ្ឋាន សមភាពយេនឌ័រ លោកស្រី តែ រួចលីម ប្រធាននាយកដ្ឋានផែនការនិងស្ថិតិ និងសមាជិក ផ្សេងៗទៀតមកពីនាយកដ្ឋានបច្ចេកទេសនានាចំណុះក្រសួងកិច្ចការនារី។ ក្រុមការងារមាន ការគាំទ្រផ្នែកបច្ចេកទេសពីគម្រោង **ភាពជាដៃគូដើម្បីសមធម៌យេនឌ័រ** (PGEIII) ដែលមាន លោកស្រី Mia Hyun ជាទីប្រឹក្សាជាន់ខ្ពស់ប្រចាំក្រសួងកិច្ចការនារី ជាអ្នកសម្របសម្រួល ទូទៅ គាំទ្រដោយក្រុមអ្នកជំនាញតាមវិស័យរបស់គម្រោង រួមមាន លោកស្រី ឌី ម៉ានី លោក ប៉ែន បូរី លោកស្រី ហេង សិលទិ លោក ឈន ថាវរិទ្ធិ និង លោក គឹម សុពណ៌។ **ក្រុមការងារបច្ចេកទេសយេនឌ័រ** (TWG-G) បានផ្តល់ជាវេទិកាដ៏សំខាន់ក្នុងការពិគ្រោះ យោបល់ជាមួយអ្នកពាក់ព័ន្ធ និងក្រុមអ្នកជួយកែសម្រួល (peer reviewers) ដែលជាអ្នក ជំនាញមកពីក្រសួងកិច្ចការនារី ក្រសួងពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ និងសង្គមស៊ីវិល បានជួយ ពិនិត្យ ឡើងវិញលើសេចក្តីព្រាងតាមជំនាញពាក់ព័ន្ធ។ បច្ចេកទេសទាក់ទងនឹងរូបភាព ការរចនា និងសម្ភារៈសម្រាប់ផ្សព្វផ្សាយផ្តល់ដោយ Good Morning Beautiful ។

**ក្រុមអ្នកដឹកនាំនិងរៀបចំជំពូកទី៩៖** ជំពូកនេះដឹកនាំរៀបចំដោយ លោកជំទាវ ខៀវ សិរីវុឌ្ឍា អគ្គនាយិកាក្រសួងកិច្ចការនារី និងចងក្រងសេចក្តីព្រាងដោយ លោក Rodrigo Montero Cano ក្រោមការឧបត្ថម្ភពីក្រសួងសហប្រតិបត្តិការនិងអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់ ប្រទេសអាល្លឺម៉ង់ (BMZ) និងក្រសួងសហប្រតិបត្តិការអន្តរជាតិនិងពាណិជ្ជកម្ម នៃ ប្រទេសអូស្ត្រាលី (DFAT) ដោយមានការផ្តល់ជាតុចូលបន្ថែមពី DFAT, Plan International, HelpAge Cambodia, UNFPA, និងគម្រោង Cambodian Defenders.

ក្រសួងកិច្ចការនារី
ផ្លូវទ្រុងមាន់ ភូមិដំណាក់ធំ ៣ សង្កាត់ស្ទឹងមានជ័យ
ក្រុងភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ហ្វាក់ : (+៨៥៥) ២៣ ៨៨០ ៧៣៧
អ៊ីម៉ែល : mwa@online.com.kh
វេបសាយ : www.mowa.gov.kh
ហ្វេសប៊ុក : www.facebook.com/mowa.gov.kh